# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច
# សម្រាប់
# គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
# ក្នុងប្រទេសកម្ពុជា

*សម្រាប់៖*

**ក្រុមធនាគារពិភពលោក**

១៨១៨ H STREET NW WASHINGTON, DC, USA ២០៤៣៣

*ដោយ៖*

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

លេខ ៤៥ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ១២២០៥

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

កែងមហាវិថីព្រះនរោត្តម និងផ្លូវលេខ១០៦ រាជធានីភ្នំពេញ ១២០០០

ខែធ្នូ ឆ្នាំ២០១៨

# មាតិកា


បញ្ជីអក្សរកាត់ ....................................................................................................4

អារម្ភកថា ..........................................................................................................6

ខ្លឹមសារសង្ខេប .......................................................................................................7

១. សេចក្តីផ្តើម ......................................................................................................16

២. គោលបំណងនៃក្របខ័ណ្ឌ ....................................................................................16

៣. ការពិពណ៌នាអំពីគម្រោង .....................................................................................17

៤. ទិដ្ឋភាពទូទៅនៃប្រជាជនជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ............................................ 20

៥. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ..........................................................................24

៥.១ គោលនយោបាយ ច្បាប់ វិធាន និងបទប្បញ្ញត្តិ របស់ប្រទេសកម្ពុជាអនុវត្តចំពោះជនជាតិដើមភាគតិច ........................................................................................................24

៥.២ កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា..............................................26

៥.៣ គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោក ) ជនជាតិដើមភាគតិច :OP៤.១០ ) .........26

៥.៤ ការវិភាគអំពីគម្លាត ...................................................................................27

៦. ការពិនិត្យ និងការវាយតម្លៃសង្គមបឋម...........................................................................28

៦.១ ការពិនិត្យ ..........................................................................................28

៦.២ លទ្ធផលនៃការវាយតម្លៃសង្គមបឋម............................................................................28

៦.៣ ផលប៉ះពាល់ដែលអាចកើតមានចំពោះជនជាតិដើមភាគតិច ..............................................29

៧. យន្តការអនុវត្តការរៀបចំ ការតាមដាន និងបណ្តឹងសារទុក្ខ .............................................. 30

៧.១ ការរៀបចំការអនុវត្ត ............................................................................... 30

៧.២ ការតាមដាន ការចងក្រងឯកសារ ការធ្វើរបាយការណ៍សម្រាប់ WaSSIP .............................33

៧.៣ តម្លាភាព និងយន្តការបណ្តឹងសារទុក្ខ ............................................................................34

៧.៣ ការកសាងសមត្ថភាព ................................................................................37

៧.៤ កាលវិភាគ ............................................................ 37
៧.៤ ថវិកា ............................................................ 37

៨. ការវាយតម្លៃសង្គមនិងការរៀបចំផែនការជនជាតិដើមភាគតិច ............................................................ 38
៨.១ វិធីសាស្ត្រប្រើប្រាស់សម្រាប់ការវាយតម្លៃសង្គម ............................................................ 38
៨.២ ការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុន ............................................................ 39

ឧបសម្ព័ន្ធទី ១ :គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការពិគ្រោះយោបល់ និងការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPP) ព្រមទាំងឯកសារស្តីពីវិធានការការពារផ្សេងទៀត ............................................................ 42

ឧបសម្ព័ន្ធទី ២: ការពិនិត្យឋមចំពោះជនជាតិដើមភាគតិច ............................................................ 50

# បញ្ជីអក្សរកាត់

| | |
|---|---|
| ARAP | Abbreviated Resettlement Action Plan<br>ផែនការសកម្មភាពសង្ខេបនៃការតាំងទីលំនៅជាថ្មី |
| ECOP | Environmental Code of Practice<br>ក្រមប្រតិបត្តិផ្នែកបរិស្ថាន |
| EIA | Environmental Impact Assessment<br>ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EMF | Environmental Management Framework<br>ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន |
| EMP | Environment Management Plan<br>ផែនការគ្រប់គ្រងបរិស្ថាន |
| ESIA | Environment and Social Impact Assessment<br>ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| ESMF | Environmental and Social Management Framework<br>ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | Environmental and Social Management Plan<br>ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESSAF | Environmental and Social Screening and Assessment Framework<br>ក្របខ័ណ្ឌពិនិត្យនិងវាយតម្លៃបរិស្ថាន និងសង្គម |
| IDA | International Development Association<br>សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IEIA | Initial Environmental Impact Assessment<br>ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើមដំបូង |
| IPO | Indigenous People Organization<br>អង្គការជនជាតិដើមភាគតិច |
| IPP | Indigenous People Plan<br>ផែនការអភិវឌ្ឍជនជាតិដើមភាគតិច |
| IPPF | Indigenous People Planning Framework<br>ក្របខ័ណ្ឌកសាងផែនការជនជាតិដើមភាគតិច |

| | |
|---|---|
| ISDS | Integrated Safeguards Data Sheet<br>សន្លឹកទិន្នន័យសមាហរណកម្មស្តីពីវិធានការការពារ |
| MoE | Ministry of Environment<br>ក្រសួងបរិស្ថាន |
| NGO | Non-Government Organization<br>អង្គការមិនមែនរដ្ឋាភិបាល |
| PRA | Participatory Rapid Assessment<br>ការវាយតម្លៃរហ័សដែលមានការចូលរួម |
| RGC | Royal Government of Cambodia<br>រាជរដ្ឋាភិបាលកម្ពុជា |
| RPF | Resettlement Policy Framework<br>ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មី |
| ROW | Right of Way<br>ចិញ្ចើមផ្លូវ |
| SDG | Sustainable Development Goals<br>គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SESA | Strategic Environmental and Social Assessment<br>ការវាយតម្លៃជាយុទ្ធសាស្ត្រផ្នែកបរិស្ថាន និងសង្គម |
| TEGs | Technical Environmental Guidelines<br>គោលការណែនាំបច្ចេកទេសផ្នែកបរិស្ថាន |
| WaSSIP | Water Supply and Sanitation Improvement Project<br>គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ |
| WB | World Bank<br>ធនាគារពិភពលោក |

# អារម្ភកថា

ឯកសារវិធានការការពារផលប៉ះពាល់នេះមានឈ្មោះថា ក្របខ័ណ្ឌកសាងផែនការជនជាតិដើមភាគតិច (IPPF) ជាឯកសារដែលរៀបចំឡើងសម្រាប់គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅកម្ពុជា (WaSSIP)។ ឯកសារនេះត្រូវបានបង្កើតឡើងលើមូលដ្ឋាននៃលទ្ធផលពីការវាយតម្លៃសង្គម (SA)។ IPPF ជាផ្នែកមួយនៃលិខិតុបករណ៍ការពារផលប៉ះពាល់ជារួម ពោលគឺក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់គម្រោង WaSSIP។ IPPF នេះនឹងត្រូវអនុវត្តចំពោះការវិនិយោគទាំងអស់ដែលផ្តល់ហិរញ្ញប្បទានដោយក្រុមធនាគារពិភពលោក (WB) សម្រាប់ការគាំទ្របច្ចេកទេស និង/ឬហិរញ្ញវត្ថុពីគម្រោងនេះ។

គម្រោងនេះមានសមាសភាគចំនួនពីរ ដូចបានបញ្ជាក់ក្នុងផ្នែកទី ៣ នៃឯកសារនេះ។ គម្រោងនេះនឹងត្រូវអនុវត្តដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន។ ការអនុវត្តវិធានការការពារផលប៉ះពាល់នេះនឹងត្រូវអនុវត្តដោយមន្ត្រីសម្របសម្រួលផ្នែកគាំពារសង្គម និងបរិស្ថាននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន។

ឯកសារនេះត្រូវបានចាត់ទុកជាឯកសាររស់ និងត្រូវធ្វើការកែតម្រូវ និងធ្វើបច្ចុប្បន្នភាពទៅតាមស្ថានភាពប្រែប្រួល ឬទៅតាមទំហំនៃសកម្មភាព។ ការពិគ្រោះយោបល់ជិតស្និទ្ធជាមួយធនាគារពិភពលោក និងការព្រមព្រៀងទៅលើ IPPF គឺជាការចាំបាច់។

# ខ្លឹមសារសង្ខេប

## សេចក្ដីផ្ដើម

១. **គោលបំណងនៃការអភិវឌ្ឍគម្រោង** ( PDO) គឺដើម្បីបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាត សេវាកម្មអនាម័យ និងពង្រឹងដំណើរការប្រតិបត្តិរបស់អ្នកផ្ដល់សេវាកម្មនៅតាមទីក្រុង ឬតំបន់ដែលបានជ្រើសរើស។

២. **សមាសភាគគម្រោង៖** គម្រោងនេះនឹងមានសមាសភាគពីរ។ សមាសភាគទី ១ សម្រាប់ការផ្គត់ផ្គង់ទឹកនៅខេត្តមណ្ឌលគិរី ទីរួមស្រុកស្នោង និងស្រុកភ្នំព្រឹក រីឯសមាសភាគទី ២ សម្រាប់លើកកម្ពស់អនាម័យខេត្ត នៅខេត្តសៀមរាបនិងនៅតំបន់ផ្សេងៗទៀត។

៣. **ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច៖** គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោក ៤.១០ ស្ដីពីជនជាតិដើមភាគតិចត្រូវបានផ្ដួចផ្ដើមសម្រាប់គម្រោងនេះដោយសារតែមានជនជាតិដើមភាគតិចរស់នៅក្នុងតំបន់អនុវត្តគម្រោង។ ដោយអនុលោមតាម OP ៤.១០ និងដំណាក់កាលមុនពេលវាយតម្លៃគម្រោង ក្របខ័ណ្ឌផែនការសម្រាប់ជនជនជាតិដើមភាគតិច (IPPF) ត្រូវបានរៀបចំ ជំនួសឱ្យផែនការអភិវឌ្ឍជនជាតិដើមភាគតិច ដោយសារទីតាំងជាក់លាក់នៃការវិនិយោគគម្រោងអាចមានផលប៉ះពាល់ ឬផ្ដល់អត្ថប្រយោជន៍ផ្ទាល់សម្រាប់ជនជាតិដើមភាគតិច គេនៅមិនទាន់ដឹងនៅឡើយលុះណាតែឈានដល់ដំណាក់កាលអនុវត្ត។ ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិចបង្ហាញពីអ្វីដែលតម្រូវឱ្យមាននៅក្នុង OP ៤.១០ ទាក់ទងនឹងការរៀបចំផែនការជនជាតិដើមភាគតិច ក៏ដូចជាធានាឱ្យមានការពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ និងប្រកបដោយខ្លឹមសារត្រឹមត្រូវជាមួយជនជាតិដើមភាគតិចលើមូលដ្ឋាននៃការពិគ្រោះយោបល់ដោយសេរី និងជូនដំណឹងជាមុន (FPIC) នាំឱ្យមានការ គាំទ្រសហគមន៍ទូលំទូលាយពីសហគមន៍ចំពោះអន្តរាគមន៍របស់គម្រោង ដែលពួកគេនឹងមានឱកាសទទួលបាននូវអត្ថប្រយោជន៍របស់គម្រោង ព្រមជាមួយនឹងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន។ IPPF នឹងបង្កើតជាមូលដ្ឋានមួយសម្រាប់ការអនុវត្តគម្រោង និងសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃអំពីរបៀបដែលគម្រោងដោះស្រាយបញ្ហាជាមួយជនជាតិដើមភាគតិច។ នៅដំណាក់កាលអនុវត្តគម្រោងផែនការជនជាតិដើមភាគតិច (IPP) នឹងត្រូវបានបង្កើតឡើងដោយផ្អែកលើ IPPF បន្ទាប់ពីមានការបញ្ជាក់ច្បាស់លាស់ពីទីតាំងវិនិយោគដែលទំនងជាមានផលប៉ះពាល់ ឬផ្ដល់អត្ថប្រយោជន៍ផ្ទាល់សម្រាប់ជនជាតិដើមភាគតិច។

## សាវតារ និងក្របខ័ណ្ឌគោលនយោបាយ

៤. **តើជនជាតិដើមជានរណា៖** នៅក្នុងច្បាប់ និងគោលនយោបាយនានា រដ្ឋាភិបាលកម្ពុជាបានចែង ជនជាតិដើមថាជា"ជនជាតិដើមភាគតិច"។ ជនជាតិដើមភាគតិចត្រូវបានគេស្គាល់ដាច់ដោយឡែកពីក្រុមជនជាតិនានា ដូចជា ជនជាតិឡាវ ដែលរស់នៅភាគឦសាន្តនៃប្រទេសកម្ពុជា ជាទូទៅមិនត្រូវបានចាត់ទុកថាជា "ជនជាតិដើម" នោះទេ រីឯជនជាតិចាម ឬជនជាតិវៀតណាម ក៏មិនត្រូវបានចាត់ទុកថាជាជនជាតិដើមដែរ។ ទោះជាយ៉ាងណាក្ដី ទស្សនៈអំពីជនជាតិដើមភាគតិចពុំមានលក្ខណៈច្បាស់លាស់ឡើយ ហើយជនជាតិខ្មែរ (ក្រុមជនជាតិភាគច្រើន) រស់នៅក្នុងតំបន់មួយចំនួន មានចរិតលក្ខណៈជាច្រើនជាជនជាតិដើមភាគតិច។ ទាក់ទងទៅនឹងគោលនយោបាយរបស់

ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច អ្នកទាំងនោះត្រូវបានចាត់ទុកថាជាអ្នកដែលមានចរិតលក្ខណៈដូចខាងក្រោមៈ

(ក) ការកំណត់អត្តសញ្ញាណកម្មដោយខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចដោយឡែកណាមួយ ហើយអត្តសញ្ញាណនេះត្រូវបានទទួលស្គាល់ពីអ្នកដទៃ។

(ខ) មានការផ្សារភ្ជាប់ជាសមូហភាពទៅនឹងទីជម្រកច្បាស់លាស់តាមភូមិសាស្ត្រ ឬដែនដីដូនតានៅក្នុងតំបន់អនុវត្តគម្រោង និងចំពោះធនធានធម្មជាតិនៅក្នុងទីជម្រក និងដែនដីទាំងនះ

(គ) ស្ថាប័នវប្បធ៌មប្រពៃណី សេដ្ឋកិច្ច សង្គម ឬនយោបាយ ដែលដាច់ដោយឡែកពីអ្នកមានប្រៀបផ្នែកសង្គម និងវប្បធម៌ និង

(ឃ) ភាសាជនជាតិដើម ដែលច្រើនតែខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។

៥. **ក្រុមជនជាតិដើមភាគតិចៈ** ក្នុងចំណោមប្រជាជនកម្ពុជាទាំងអស់ ជនជាតិខ្មែរមានចំនួនប្រមាណ ៩០-៩៥ ភាគរយ។ ចំនួន ៥-១០ ភាគរយផ្សេងទៀត រួមមាន ជនជាតិភាគតិចនានា ដូចជា ចាមមូស្លីម ចិន និងវៀតណាម និងជនជាតិភាគតិចចំនួនដប់ប្រាំពីរក៏ត្រូវបានគេហៅថា "ខ្មែរលើ" ឬ "កុលសម្ព័ន្ធភ្នំ" ជាជនជាតិមិនមែនខ្មែរ។ ក្រុមទាំងនេះត្រូវបានគេប៉ាន់ស្មានថាមានចំនួនប្រហែល ១២០.០០០ នាក់ និងមានចំនួនប្រមាណជា ១% នៃចំនួនប្រជាជនកម្ពុជាសរុប។ ក្រុមជនជាតិដើមភាគតិចចំនួនទាំងដប់ប្រាំពីរដែលមានចាប់ពី ៣០០ នាក់ទៅ ១៩០០០ នាក់ រួមមាន ព្នង គួយ មិល ក្រោល ថ្មុន ខោញ ទំពួន ចារ៉ាយ គ្រឹង កាវេត ស្អូច លុន កាចក់ ព្រៅ សួយ(សាអុង) ស្ទៀង និងកាវេត និងក្រុមជនជាតិភាគតិចដទៃទៀត គឺវៀតណាម ឡាវ និងខ្មែរអ៊ិស្លាម[1]។ ក្រុមជនជាតិដើមភាគតិចភាគច្រើននៅនៅខេត្តរតនគិរី (៦៧,៩ ភាគរយ) និងមណ្ឌលគិរី (៥៩,៣ ភាគរយ) ។ ស្ទឹងត្រែង និងក្រចេះក៏មានអត្រាខ្ពស់នៃក្រុមជនជាតិដើមភាគតិចរស់នៅផងដែរ។

## <u>គោលនយោបាយ ច្បាប់ វិធាន និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជាអនុវត្តចំពោះជនជាតិដើមភាគតិច</u>

៦. **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិចៈ** គោលនយោបាយនេះត្រូវបាន អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែមេសាឆ្នាំ ២០០៩ និងដាក់ចេញនូវគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងជនជាតិដើមភាគតិចនៅក្នុងវិស័យវប្បធម៌អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខភាព បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។ រួមជាមួយច្បាប់ភូមិបាល (ឆ្នាំ ២០០១) គោលនយោបាយនេះផ្តល់នូវការទទួលស្គាល់ចំពោះសិទ្ធិជនជាតិដើមភាគតិចចំពោះដីប្រពៃណី វប្បធម៌ និងទំនៀមទម្លាប់។

---

*[1] ផ្លូវទៅកេយុត្តិធម៌៖ ការទទួលបានយុត្តិធម៌ដោយផ្តោតលើស្ត្រីក្រីក្រនិងជនជាតិដើមភាគតិចក្រសួងយុត្តិធម៌ យូអិនឌីភី ខែកញ្ញា ឆ្នាំ២០០៥ ទំព័រ ៥៩ ។*

៧. **គោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់សហគមន៍ជនជាតិដើមភាគតិច** នៅប្រទេសកម្ពុជាត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែមេសាឆ្នាំ ២០០៩ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៩ ខែមិថុនាឆ្នាំ ២០០៩ ដោយ នាយករដ្ឋមន្ត្រី។ គោលនយោបាយនេះជាមូលដ្ឋាននៃការទទួលស្គាល់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ នូវសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការកាន់កាប់និងប្រើប្រាស់ដីជាកម្មសិទ្ធិជាសមូហភាពរបស់ពួកគេ។

៨. **រដ្ឋធម្មនុញ្ញកម្ពុជា (ឆ្នាំ ១៩៩៣)៖** មាត្រា ៣១.២ ចែងថា "ពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះច្បាប់និងមានសិទ្ធិសេរីភាពនិងមានសិទ្ធិ សេរីភាព និងករណីកិច្ចដូចៗគ្នា ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ទំនោរផ្នែកនយោបាយ កំណើតប្រភពដើម ស្ថានភាពសង្គម ធនធាន និងស្ថានភាពឯទៀតឡើយ "។ ជនជាតិដើមភាគតិចគឺជាពលរដ្ឋកម្ពុជា។

៩. **ច្បាប់ភូមិបាលឆ្នាំ ២០០១** ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ជាម្ចាស់អចលនវត្ថុ ជាដីរបស់ពួកគេ ដែលមានប័ណ្ណកម្មសិទ្ធិសមូហភាព។ មាត្រា ២៣ នៅក្នុងច្បាប់កំណត់សហគមន៍ជនជាតិដើមភាគតិចថាជា:

- ក្រុមមនុស្សដែលបង្ហាញពីឯកភាពជាតិពិន្ទុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច
- អ្នករស់នៅបែបប្រពៃណី និង
- អ្នកដាំដុះលើដីដែលពួកគេកាន់កាប់តាមទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព

១០. **ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២** (មាត្រា ១១ ១៥ ១៦ ៤០) ធានានិងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការបន្តការប្រើប្រាស់ និងចូលទៅកាន់តំបន់ព្រៃមួយចំនួនដែលក្រុមទាំងនេះប្រើប្រាស់តាមបែបប្រពៃណី និងការអនុវត្តរបៀបរស់នៅរបស់ពួកគេក្នុងការអាស្រ័យផលពីព្រៃឈើ។

**<u>កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធដែលកម្ពុជាបានធ្វើ</u>**

១១. យោងតាមវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ប្រទេសកម្ពុជាគឺជាហត្ថលេខីលើឧបករណ៍អន្តរជាតិមួយចំនួនដែលការពារសិទ្ធិរបស់ជនជាតិដើមភាគតិច[2] ក៏ដូចជាអនុសញ្ញាស្តីពីជីវៈចម្រុះ (១៩៩២) ដែលទទួលស្គាល់តួនាទីរបស់ជនជាតិដើមភាគតិចក្នុងការការពារជីវចម្រុះ។ នៅឆ្នាំ ១៩៩២ រដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ ការណ៍នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការអនុវត្តវប្បធម៌ជាក់លាក់ និងសិទ្ធិទទួលបានមធ្យោបាយចិញ្ចឹមជីវិត។ **សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច**ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅខែកញ្ញាឆ្នាំ២០០៧។ ប្រទេស ជាច្រើនក្នុងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ បានបោះឆ្នោតគាំទ្រសេចក្តីប្រកាសដែលមិនជាប់

---

[2] រួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធសង្គម និងសិទ្ធិវប្បធម៌ (ICESCR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច និងជាទូទៅគឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

កាតព្វកិច្ច។ **អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)** មាត្រា ៥ (e) ធានានូវភាពស្មើគ្នា និងគ្មានការរើសអើងសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ជាពិសេសសិទ្ធិទទួលការអប់រំ និងការបណ្តុះបណ្តាល ។

**<u>គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោក: ជនជាតិដើមភាគតិច (OP៤.១០)</u>**

១២. គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោក ៤.១០ (ជនជាតិដើមភាគតិច) តម្រូវឱ្យមានវិធានការណ៍កសាងផែនការពិសេស ដើម្បីការពារផលប្រយោជន៍របស់ជនជាតិដើមភាគតិចដែលមានអត្តសញ្ញាណសង្គម និងវប្បធម៌ខុសគ្នាពីអត្តសញ្ញាណសង្គម និងវប្បធម៌របស់សង្គមភាគច្រើនដែលអាចធ្វើឱ្យពួកគេងាយរងគ្រោះក្នុងដំណើរការអភិវឌ្ឍ។ បុរេលក្ខខណ្ឌមួយសម្រាប់ការអនុម័តគម្រោង OP ៤.១០ តម្រូវឱ្យអ្នកខ្ចីធ្វើការពិគ្រោះយោបល់ដោយសេរី និងផ្តល់ដំណឹងជាមុន ដល់ជនជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ និងបង្កើតលំនាំនៃការគាំទ្រសហគមន៍ទូលំទូលាយសម្រាប់គម្រោងនិងគោលបំណងរបស់គម្រោងនេះ។ ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា OP ៤.១០ សំដៅដល់ក្រុមសង្គមនិងសហគមន៍នានា ពោលគឺពុំមែនសំដៅដល់បុគ្គលឡើយ។

**<u>ការវិភាគអំពីគម្លាត/ភាពខុសគ្នា</u>**

១៣. ទោះបីជាប្រទេសកម្ពុជាមានគោលនយោបាយដែលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចចំពោះវប្បធម៌ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុខភាព បរិស្ថាន ដីធ្លី កសិកម្មធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែនិងថាមពលក្តី គេឃើញក្រឹត្យ អនុក្រឹត្យ ឬនីតិវិធីតិចតួចប៉ុណ្ណោះដែលគាំពារ ឬការពារផលប្រយោជន៍ជាពិសេសរបស់ជនជាតិដើមភាគតិច។ ជាទូទៅពួកគេត្រូវបានគេចាត់ទុកដូចពលរដ្ឋខ្មែរដែរ។ ករណីលើកលែងនោះ គឺច្បាប់ភូមិបាលរបស់កម្ពុជាបានទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ក្នុងការមានកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិដីធ្លីរបស់ពួកគេ។ ជាក់ស្តែង នីតិវិធីដើម្បីចុះបញ្ជីសមូហភាពត្រូវចំណាយពេលយ៉ាងយូរហើយមានសហគមន៍ជនជាតិដើមភាគតិចតិចតួចប៉ុណ្ណោះ (ប្រហែល ៥) បានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពចាប់តាំងពីច្បាប់ភូមិបាលបានអនុម័តក្នុងឆ្នាំ២០០១ មក។ ស្រដៀងគ្នានេះដែរច្បាប់ព្រៃឈើក៏ធានានិងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការបន្តការប្រើប្រាស់ និងការចូលទៅកាន់តំបន់ព្រៃឈើមួយចំនួនដែលពួកគេប្រើប្រាស់ និងអនុវត្តតាមបែបប្រពៃណី។ ពុំនោះទៀតសោត ភាពខុសគ្នាចម្បងរវាងកិច្ចតម្រូវរបស់ធនាគារពិភពលោក និងគោលនយោបាយរបស់រាជរដ្ឋា ភិបាលកម្ពុជាជាប់ទាក់ទងនឹងអវត្តមាននៃក្រឹត្យ ឬនីតិវិធីនិយាមប្រតិបត្តិជាក់លាក់តាមវិស័យ។ ចំណុចនេះផ្ទុយគ្នាពីគោលនយោបាយរបស់ធនាគារពិភពលោកដែលទាមទារឱ្យមាននីតិវិធី និងផែនការលម្អិតដើម្បីការពារជនជាតិដើមភាគតិច។ ហេតុដូច្នេះ IPPF នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន OP៤.១០ របស់ធនាគារពិភពលោក ដោយពិចារណាលើគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ប្រទេសកម្ពុជា។ យន្តការច្បាស់លាស់ សម្រាប់ការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុន ដើម្បីស្វែងរកការគាំទ្រយ៉ាងទូលំទូលាយចំពោះសកម្មភាពគម្រោងពីសហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលអនុវត្ត។ ក្នុងអំឡុងពេលនៃការអនុវត្ត យន្តការដោះស្រាយបណ្តឹងសារទុក្ខនឹង

ត្រូវបង្កើតឡើងដើម្បីឱ្យជនជាតិដើមភាគតិចអាចបញ្ចេញមតិតាមរយៈបណ្ដឹងតវ៉ា ឬការផ្ដល់យោបល់ចំពោះគម្រោងនេះ។

**បញ្ហាសំខាន់ៗ និងផលប៉ះពាល់ដែលអាចកើតមានក្នុងបញ្ហាជនជាតិដើមភាគតិច**

**<u>ការពិនិត្យមើលវត្តមាននៃជនជាតិដើមភាគតិចនិងការពិគ្រោះយោបល់បឋម</u>**

១៤. ការចុះពិនិត្យដល់ទីកន្លែង និងការស្រាវជ្រាវឯកសារដោយអ្នកឯកទេសផ្នែកអភិវឌ្ឍន៍សង្គមរបស់ធនាគារពិភពលោកនៅ ខែមិថុនាឆ្នាំ ២០១៨ បានរកឃើញថាជនជាតិដើមភាគតិច ភាគច្រើនមានវត្តមាននៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តក្រចេះ (ភាគឦសាននៃប្រទេសកម្ពុជា) ។ ក្រុមជនជាតិភាគតិចតូចៗផ្សេងទៀតកំពុងរស់នៅក្នុងខេត្តព្រះវិហារ (គួយ) ខេត្តកំពង់ស្ពឺ (សួយ) ព្រះសីហនុ (ស្អូច) ខេត្តកំពង់ចាម (ស្ទៀង)ខេត្តកំពង់ធំ (គួយ) ខេត្តបន្ទាយមានជ័យ (គួយ) ខេត្ត ឧត្តរមានជ័យ (ចម្រុះ)។ សហគមន៍ជនជាតិដើមភាគតិចទាំងអស់មានទីតាំងស្ថិតនៅតំបន់ដាច់ស្រយាលនៃខេត្តដែលពិបាកទៅដល់ (គ្មានផ្លូវល្អ) ហើយមិនសូវមានហេដ្ឋារចនាសម្ព័ន្ធ។ នៅមណ្ឌលគិរីការសម្ភាសន៍ពីផ្ទះមួយទៅផ្ទះមួយដែលធ្វើឡើងដោយនាយក ដ្ឋានបណ្ដាញចែកចាយទឹកបានបញ្ជាក់ថា ជនជាតិដើមភាគតិច ភាគច្រើនគ្មានការផ្គត់ផ្គង់ទឹកស្អាត និងបានបង្ហាញពីឆន្ទៈរបស់ពួកគេក្នុងការប្រើប្រាស់ទឹកស្អាត។

**<u>លទ្ធផលបឋមនៃការវាយតម្លៃសង្គម</u>**

១៥. ការពិនិត្យមើលបឋមឃើញថា គម្រោងទឹកស្អាតនៅមណ្ឌលគិរី អាចមានការប៉ះពាល់ដល់សហគមជនជាតិដើមភាគតិច។ នៅដំណាក់កាលទី ១ នៃគម្រោង (ការពង្រីកបណ្ដាញទឹកស្អាតក្នុងក្រុងសែនមនោរម្យ) ទោះបីជាបណ្ដាញតភ្ជាប់ទឹកនៅក្នុងក្រុងសែនមនោរម្យនឹងមិនទៅដល់សហគមន៍ជនជាតិដើមភាគតិចក៏ដោយ ជនជាតិដើមភាគតិចមួយចំនួនកំពុងរស់នៅតាមបណ្ដោយផ្លូវបច្ចុប្បន្ន ដែលនឹងមានការតម្លើងតភ្ជាប់បំពង់ទឹកថ្មី។ ដំណាក់កាលទី ២ នៃការងារដែលត្រូវផ្ដល់ហិរញ្ញប្បទានក្រោមគម្រោងនេះ នឹងមិនត្រូវបានបង្កើតឡើងរហូតដល់គម្រោងនេះស្ថិតនៅក្នុងការអនុវត្ត គឺក្នុងដំណាក់កាលនេះហើយដែលមានការរំពឹងថានឹងពង្រីកបណ្ដាញទឹកនៅទូទាំងសហគមន៍ជនជាតិដើមភាគតិច។ ជារួម WaSSIP មានអត្ថប្រយោជន៍ដល់សង្គម។ សមាសភាគអនុគម្រោងត្រូវបានគេរំពឹងថានឹងប្រើប្រាស់បច្ចេកវិទ្យាសាមញ្ញ សមស្រប និងចំណាយតិចដែលមិនបង្កផលវិបាកច្រើនដល់សង្គមនោះទេ។ ការផ្ដល់ទឹកស្អាតដែលមានសុវត្ថិភាពត្រូវបានរំពឹងថានឹងផ្ដល់ផលវិជ្ជមានយ៉ាងច្រើនលើការកែលម្អជីវភាពរស់នៅ។ ផលប៉ះពាល់អវិជ្ជមានបណ្ដោះអាសន្នមួយចំនួនតូចអាចកើតមានចំពោះបរិស្ថានអាចកើតមានបណ្ដាលមកពីសកម្មភាពសាងសង់។ ផលប៉ះពាល់ទាំងនេះអាចគ្រប់គ្រងបានយ៉ាងងាយដោយវិធានការកាត់បន្ថយស្តង់ដារសំណង់ស៊ីវិល ដូចជាការដាក់កម្រិតកំណត់លើម៉ោងធ្វើការ ការគ្រប់គ្រងធូលីតាមរយៈការស្រោចទឹក និងការគ្រប់គ្រងការហូរច្រោះ និងកំណកដី។

## យន្តការចាត់ចែងអនុវត្ត ត្រួតពិនិត្យ សារទុក្ខ និងរាយការណ៍

### ការចាត់ចែងអនុវត្តន៍

១៦. ការអនុវត្តន៍ IPPF នឹងអនុវត្តតាមរចនាសម្ព័ន្ធអនុវត្តគម្រោង។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបង្កើតផ្នែកគ្រប់គ្រងសមាសភាគ ១ (CMU-១) សម្រាប់សមាសភាគទី ១ ហើយក្រសួងសាធារណៈការនិងដឹកជញ្ជូន នឹងបង្កើតផ្នែកគ្រប់គ្រងសមាសភាគ ២ (CMU-២) សម្រាប់សមាសភាគទី ២ ។ CMU-១ និង CMU-២ នឹងដឹកនាំការអនុវត្តគម្រោងប្រចាំថ្ងៃ ទទួលបន្ទុកលើការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ពិនិត្យតាមដាន វឌ្ឍនភាពគម្រោង និងធ្វើការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ធានានូវការអនុលោមជាមួយវិធានការការពារសង្គម និង បរិស្ថានរបស់គម្រោង រៀបចំរបាយការណ៍គម្រោងត្រួតពិនិត្យសំណង់ស៊ីវិល សំរបសំរួលនិងប្រមូលធាតុចូលពីក្រសួងពាក់ព័ន្ធទាក់ទងនឹងសមាសភាគគម្រោងរៀងៗខ្លួន។

១៧. **មន្ត្រីសម្របសម្រួលការគាំពារសង្គមពីររូប**ត្រូវបានតែងតាំងដោយក្រសួងឧស្សាហកម្ម និងសិប្បកម្មសម្រាប់សមាសភាគទី១ និងដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន សម្រាប់សមាសភាគទី២ ដើម្បីទទួលខុសត្រូវលើការអនុលោមការពារតាម IPPF ដែលបានអនុម័ត និង IPP ដែលអាចធ្វើបាន។ ការទទួលខុសត្រូវរួមមានជាអាទិ៍ (ក) សកម្មភាពអនុវត្តទៅតាម IPPF ហើយធានាថាជនជាតិដើមភាគតិច និងជនងាយរងគ្រោះទទួលបានអត្ថប្រយោជន៍ពីគម្រោង (ខ) - រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ និងការវាយតម្លៃសង្គមនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដើម្បីកំណត់តម្រូវការសម្រាប់តំបន់អនុវត្តគម្រោងជាក់លាក់ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានបណ្តាលមកពីការអនុវត្តរបស់គម្រោងជាក់លាក់នៅតាមតំបន់ និងអន្តរាគមន៍ដែលអាចមានចំពោះគម្រោង (គ) ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំដោយរៀបរាប់លម្អិតអំពីការផ្សព្វផ្សាយព័ត៌មាន បញ្ហាពិភាក្សា បញ្ហាកង្វល់ ដែលលើកឡើងដោយ IP និងអន្តរាគមន៍របស់គម្រោង និង (ឃ) ធ្វើការពិគ្រោះយោបល់ និងការធ្វើបច្ចុប្បន្នភាពចំពោះការវាយតម្លៃសង្គម និងការធ្វើរបាយការណ៍។ លទ្ធផលនឹងត្រូវសង្ខេបនៅក្នុងរបាយការណ៍មួយហើយត្រូវបានបញ្ជូនទៅ CMU រៀងៗខ្លួនដែលនឹងចងក្រងរបាយការណ៍ រួចបញ្ជូនទៅធនាគារពិភពលោក។

១៨. **មន្ទីរឧស្សាហកម្ម និងសិប្បកម្មថ្នាក់ខេត្ត និងរដ្ឋាករទឹក** គឺជាការិយាល័យថ្នាក់ក្រោមជាតិរបស់ MIH ដែលជាទំនាក់ទំនងរវាង MIH និងសហគមន៍ / អាជ្ញាធរមូលដ្ឋាន។

១៩. **ទីប្រឹក្សាខាងគាំពារសង្គម** នឹងត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការគាំពារមន្ត្រីទំនាក់ទំនងសំដៅធានាឱ្យការវាយតម្លៃសង្គមត្រូវបានបំពេញ រួមជាមួយដំណើរការពិគ្រោះយោបល់ដោយសេរី និងដែលមានការផ្តល់ដំណឹងជាមុន ហើយដែលផែនការជនជាតិដើមភាគតិចត្រូវបានរៀបចំ និងអនុវត្ត។

### ការតាមដាន ការចងក្រងឯកសារ និងការផ្សព្វផ្សាយ

២០. ដោយសារវិសាលភាពនៃសំណង់ស៊ីវិលដែលត្រូវអនុវត្តនៅតាមផ្លូវដែលមានស្រាប់ក្រោមគម្រោងនេះដែលមានទំហំតូចហើយការជ្រើសរើសការវិនិយោគជាអាទិភាពនឹងអនុវត្តតាមកសាងផែនការ ដែលមានការចូលរួម និងដំណើរការពិគ្រោះយោបល់ ដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌនេះ គេមិនរំពឹងថានឹងមានផលប៉ះពាល់អវិជ្ជមាន

ធំដុំ មកលើដីធ្លីនិងធនធានរបស់ជនជាតិដើមភាគតិចឡើយ។ ដូច្នេះគម្រោងនេះត្រូវខិតខំពង្រឹងសមត្ថភាពក្នុងការតាមដានដោយខ្លួនឯងនិងសមត្ថភាពដោះស្រាយបញ្ហារបស់សហគមន៍មូលដ្ឋាន ជាអាទិ៍ សហគមន៍ជនជាតិដើមភាគតិច។ ការតាមដាន និងវាយតម្លៃដោយមានការចូលរួម នឹងត្រូវអនុវត្តន៍ក្នុងកំឡុងពេលអនុវត្ត ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់វាយតម្លៃប្រសិទ្ធភាពរបស់គម្រោង និងកំណត់វិធានការនានាដើម្បីពង្រីកអត្ថប្រយោជន៍វិជ្ជមាននិងដោះស្រាយផលប៉ះពាល់អវិជ្ជមាន។ ការណ៍នេះនឹងមានទម្រង់ជាការប្រជុំទៀងទាត់ (ប្រចាំត្រីមាស / ប្រចាំខែ) រវាងសហគមន៍អ្នកម៉ៅការ និងនាយកដ្ឋានតបណ្តាញ ទឹក ដែលជួយសម្រួលដោយការពិគ្រោះយោបល់ជាមួយប្រព័ន្ធការពារសង្គម ឬជាមួយមន្ត្រីសម្របសម្រួល។ ម្យ៉ាងទៀតថាតើទំនាស់ដែលពាក់ព័ន្ធនឹងក្រុមជនជាតិភាគតិចបានកើតឡើង ត្រូវបានដោះស្រាយដោយអនុលោមតាមឯកសារនេះនឹងត្រូវបានតាមដាន និងរាយការណ៍ដោយមន្ត្រីសម្របសម្រួល/កុងស៊ុលតង់ការពារសង្គមដែរឬយ៉ាងណា។ CMU-១ តាមរយៈមន្ត្រីសម្របសម្រួលរបស់ខ្លួននឹងធ្វើការតាមដាន និងវាយតម្លៃផ្ទៃក្នុងទៀងទាត់លើ IPPF / IPP រួមទាំងការពិនិត្យឡើងវិញនូវរបាយការណ៍វឌ្ឍនភាពប្រចាំខែដែលបានបញ្ជូនដោយវិស្វករការដ្ឋាន។

## យន្តការតម្លាភាព និងបណ្តឹងសារទុក្ខ

២១. គោលនយោបាយជនជាតិដើមភាគតិចរបស់ធនាគារពិភពលោក តម្រូវឱ្យគម្រោងវិនិយោគបង្កើតយន្តការសម្រាប់ដោះស្រាយបណ្តឹងសារទុក្ខ ដើម្បីធានាឱ្យមានការពេញចិត្តរបស់ជនជាតិដើមភាគតិចចំពោះការអនុវត្តសកម្មភាពពាក់ព័ន្ធនឹង IPPF និងផ្តល់ឱ្យជនជាតិដើមភាគតិចនូវវេទិកាស្របច្បាប់សម្រាប់ការតាមដាន និងរាយការណ៍អំពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹង IPPF ។ ជាក់ស្តែងគោលបំណងនៃយន្តការបណ្តឹងសារទុក្ខនេះគឺដើម្បីអនុញ្ញាតឱ្យជនជាតិដើមភាគតិច និងអ្នកដែលជឿថាពួកគេទទួលរងផលប៉ះពាល់ ក្នុងការស្វែងរកដំណោះស្រាយជាទីពេញចិត្តចំពោះបណ្តឹងសារទុក្ខដែលពួកគេអាចមាន ទាក់ទងនឹងលទ្ធកម្មដីធ្លី ការកំហិតលើធនធាន ឬអន្តរាគមន៍ផ្សេងទៀតរបស់គម្រោង។

២២. នៅពេលចាប់ផ្តើមអនុវត្តគម្រោង គណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខនឹងត្រូវបង្កើតឡើងនៅថ្នាក់ឃុំសង្កាត់ ស្រុក និងខេត្ត លើរចនាសម្ព័ន្ធដែលមានស្រាប់ ដែលរួមមាន នាយកដ្ឋានអង្គការក្រៅរដ្ឋាភិបាល អង្គការសហគមន៍ តំណាងស្ត្រី និងជនជាតិភាគតិច ប្រសិនបើមាន។ នៅតាមភូមិ យន្តការបណ្តឹងសារទុក្ខដែលមានស្រាប់ដែលត្រូវដឹកនាំដោយមេដឹកនាំចាស់ទុំ និង / ឬមេដឹកនាំសាសនា និងមេកុលសម្ព័ន្ធដែលមួយផ្នែកធំសហគមន៍មូលដ្ឋានអាចទទួលយកបាន ហើយនឹងត្រូវពង្រឹងជាដំណោះស្រាយបណ្តឹងសារទុក្ខកម្រិតទីមួយ។ ការរៀបចំនេះជួយធានាថាប្រព័ន្ធមួយត្រូវបានបង្កើតឡើងដើម្បីជួយដោះស្រាយបណ្តឹងសារទុក្ខ ឬដោះស្រាយពាក្យបណ្តឹងដែលអាចកើតឡើងបន្ទាប់ពីមានអន្តរាគមន៍របស់គម្រោង។ យន្តការបណ្តឹងសារទុក្ខនឹងត្រូវអនុវត្តចំពោះបុគ្គល ឬក្រុមដែលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ក៏ដូចជាអ្នកដែលមានផលប្រយោជន៍នៅក្នុងគម្រោង និង / ឬមានលទ្ធភាពធ្វើឱ្យមានឥទ្ធិពលចំពោះលទ្ធផលរបស់គម្រោងទាំងវិជ្ជមាន ឬអវិជ្ជមាន។ គម្រោងនេះនឹងផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដើម្បីពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់សំដៅដោះស្រាយប្រកបដោយប្រសិទ្ធភាព និងដោះស្រាយរួមគ្នាជាមួយបណ្តឹងសារទុក្ខដែល PAPs អាចលើកឡើងក្នុងកំឡុងវគ្គបណ្តុះបណ្តាល និងបន្ទាប់ពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។

## ការកសាងសមត្ថភាព

២៣. ការវាយតម្លៃតម្រូវការការបណ្តុះបណ្តាល (TNA) នឹងប្រព្រឹត្តទៅដើម្បីរៀបចំឯកសារបណ្តុះ បណ្តាលពាក់ព័ន្ធ នឹងតម្រូវការនោះ។ TNA នឹងធ្វើឡើងក្នុងចំណោម CMU ទីប្រឹក្សាខាងការគាំពារសង្គម និងសហគមន៍។ ការបណ្តុះបណ្តាលនឹងគ្របដណ្តប់លើគោលនយោបាយការពារ និងអនុលោមភាពចំនួនបី ពោលគឺបរិស្ថាន ការតាំងទីលំនៅដោយបង្ខំ និងជនជាតិដើមភាគតិច។ ជាមួយការបណ្តុះបណ្តាល IPPF / IPP ជាក់លាក់ រួមមាន (ក) ទិដ្ឋភាពទូទៅនៃ OP៤.១០ របស់ធនាគារ ពិភពលោក និងច្បាប់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធរបស់កម្ពុជា។ (ខ) មាតិកា និងបញ្ហាអនុវត្ត IPPF / IPP (គ) ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តគម្រោង រួមមានតួនាទី និងការទទួលខុសត្រូវ (ឃ) របៀបពិគ្រោះយោបល់ជាសាធារណៈដោយប្រើវិធីសាស្ត្រពិគ្រោះយោបល់ដោយសេរី និងផ្តល់ដំណឹងជាមុន (ង) នីតិវិធីដោះស្រាយបញ្ហា និងបណ្តឹងសារទុក្ខ និង (f) ការតម្រូវឱ្យមានការតាមដាន និងការរាយការណ៍។

## ថវិកា

២៤. ថវិកាសំរាប់ការអនុវត្ត IPPF គឺជាផ្នែកមួយនៃថវិកាគម្រោង។ ថវិកានេះនឹងប្រើដើម្បីគ្របដណ្តប់លើការចំណាយប្រាក់ឧបត្ថម្ភបុគ្គលិកគម្រោង និងចំណាយលើកុងស៊ុលតង់ក្នុងការរៀបចំរបាយការណ៍អនុលោមភាព រួមមាន របាយការណ៍ត្រួតពិនិត្យនិងតាមដាន ការប្រមូលទិន្នន័យ និងការរៀបចំ IPP ជាដើម។ ការប៉ាន់ស្មានថវិកាមាននៅក្នុងក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន(ESMF)។

**ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយជាសាធារណៈ**:

## វិធីសាស្ត្រប្រើប្រាស់សម្រាប់ការវាយតម្លៃបឋម

២៥. ទីមួយ វិធីនេះត្រូវបានគេប្រើក្នុងអំឡុងពេលកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាននិងសហគមន៍ក្នុងអំឡុងពេល SA (ដំណាក់កាលកសាងទស្សនទានគម្រោង) ។ នៅក្នុងដំណាក់កាលបន្តបន្ទាប់វិធីសាស្ត្រនេះនឹងត្រូវបានប្រើសម្រាប់ការត្រួតពិនិត្យគម្រោង ការវាយតំលៃសង្គម (ដើម្បីរៀបចំ IPP) ការអនុវត្តគម្រោង និងការត្រួតពិនិត្យ។ ដំណើរការ និងនីតិវិធីលម្អិតពណ៌នានៅផ្នែកខាងក្រោម។

២៦. ការវាយតម្លៃសង្គមបឋមបានបញ្ជាក់ថាជនជាតិដើមនៅក្នុងតំបន់អនុវត្តគម្រោង (ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី) ជារួម នឹងទទួលផលវិជ្ជមានពីគម្រោង ប៉ុន្តែអាចរងផលប៉ះពាល់អវិជ្ជមានដោយសារការយកដីសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកនៅប្រភពទឹកថ្មី និងការសាងសង់ស្ថានីយ៍បូមមួយចំនួនទៀតដែលអាចមានទីតាំងស្ថិតនៅក្នុងសហគមន៍របស់ពួកគេ។

## ការពិគ្រោះយយោបល់ដោយសេរី និងបានផ្តល់ដំណឹងជាមុន

២៧. គម្រោងនេះនឹងអនុវត្តការពិគ្រោះយោបល់ពេញលេញ និងការចូលរួមពីភាគីពាក់ព័ន្ធ។ ក្នុងអំឡុងពេលពិនិត្យពិច័យគម្រោង សហគមន៍ អ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន នឹងត្រូវបានពិគ្រោះយោបល់អំពីអត្ថប្រយោជន៍ និងផលប៉ះ

ពាល់ដែលអាចកើតមាន។ នៅក្នុងដំណើរការនេះការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុនមុននឹងប្រព្រឹត្តទៅជាភាសារបស់ជនជាតិដើមភាគតិច និងប្រព្រឹត្តទៅនៅទីតាំងដែលមានភាពងាយស្រួលសម្រាប់ជនជាតិដើមភាគតិច និងជនជាតិដើមភាគតិចដែលអាចរងផលបះពាល់។ ទស្សនៈរបស់ជនជាតិដើមភាគតិចត្រូវលើកយកមកពិចារណាក្នុងអំឡុងពេលអនុវត្តគម្រោង ទន្ទឹមជាមួយការគោរពការអនុវត្តបច្ចុប្បន្ន ការគោរពជំនឿ និងចំណង់ចំណូលចិត្តផ្នែកវប្បធម៌របស់ពួកគេ។ លទ្ធផលនៃការពិគ្រោះយោបល់នេះនឹងត្រូវចងក្រងជាឯកសារ ជារបាយការណ៍តាមកាលកំណត់ និងដាក់ជូនធនាគារពិភពលោកដើម្បីត្រួតពិនិត្យ សារជាថ្មី។ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង នឹងមានការធ្វើបច្ចុប្បន្នភាពចំពោះការវាយតម្លៃសង្គមផងដែរ ដើម្បីតាមដានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃគម្រោង និងទទួលបានមតិយោបល់ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង។ នៅមុនពេលពិគ្រោះយោបល់ មន្ទីរខេត្តនីមួយៗនឹងបញ្ជូនសេចក្តីជូនដំណឹងដល់សហគមន៍ ជម្រាបជូនដំណឹងដល់មេដឹកនាំរបស់ពួកគេថា មន្ត្រីសម្របសម្រួល និងអាជ្ញាធរដែនដីនឹងចុះមកជួបពួកគេ ហើយការពិគ្រោះយោបល់នឹងប្រព្រឹត្តទៅដើម្បីស្វែងរកការគាំទ្រពីអន្តរាគមន៍របស់គម្រោង និងកំណត់រកផលប៉ះពាល់អវិជ្ជមានក៏ដូចជាការគាំទ្រពីគម្រោងដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចកើតមានផងដែរ។ សេចក្តី ជូនដំណឹងនេះនឹងស្នើសុំឱ្យសហគមន៍អញ្ជើញតំណាងកសិករ សមាគមន៍ស្ត្រី និងមេភូមិចូលរួមប្រជុំ។ ក្នុងអំឡុងពេលទស្សនកិច្ចនេះថ្នាក់ដឹកនាំសហគមន៍ និងអ្នកចូលរួមដទៃទៀតនឹងបង្ហាញទស្សនៈរបស់ពួកគេ ទាក់ទងនឹងសកម្មភាពដែលបានស្នើឡើង។ ក្នុងអំឡុងពេលពិគ្រោះយោបល់ នីតិវិធីលម្អិតនឹងត្រូវកំណត់ទៅតាមភូមិតាមនីមួយៗ ដើម្បីកំណត់ផលប៉ះពាល់ដែលអាចកើតមាន និងការគាំទ្រដែលអាចទៅរួចនៅក្រោមគម្រោងនេះ។

២៨. **ការវាយតម្លៃសង្គម**នឹងប្រព្រឹត្តទៅនៅតាមតំបន់គោលដៅដែលបានកំណត់ថាអាចមានផលប៉ះពាល់មកលើជនជាតិដើមភាគតិច មកលើដីធ្លី និងមកលើធនធានផ្សេងទៀត។

២៩. **ប្រព័ន្ធដោះស្រាយជម្លោះ**តាមរយៈយន្តការបណ្តឹងសារទុក្ខដែលត្រូវបានបង្កើតឡើង នឹងត្រូវបានកំណត់ដើម្បីធានាឱ្យមានការពិចារណាចំពោះសម្លេងរបស់ប្រជាជនរងផលប៉ះពាល់ (ជាពិសេសចំពោះលទ្ធកម្មដីធ្លី) ។

# ១. សេចក្តីផ្តើម

១. ប្រទេសកម្ពុជាបានសម្រេចគោលដៅផ្គត់ផ្គង់ទឹកនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) និងបានធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអនាម័យ។ លទ្ធភាពទទួលបានប្រភពទឹកស្អាត និងអនាម័យកាន់តែប្រសើរឡើងមាន ៧៥ ភាគរយ និង ៤៩ ភាគរយ។ លទ្ធភាពទទួលបានទឹក និងគុណភាពនៃការផ្គត់ផ្គង់ទឹកនិងអនាម័យ នៅតែមានកម្រិតទាបជាងបណ្តាប្រទេសក្នុងតំបន់ ដោយមានប្រជាជនតែ ២១% ប៉ុណ្ណោះដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាត (៣០% នៃប្រជាជនមានប្រភពទឹកម៉ាស៊ីនមានគុណភាពមិនល្អ និង ២០% នៃប្រជាជនប្រើប្រាស់ទឹកពីប្រភពទឹកលើដី)។ ការសំរេចគោលដៅដែលមានមហិច្ឆតាខ្ពស់នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពប្រកបដោយចីរភាព (SDGs) ស្តីពីទឹកស្អាត និងអនាម័យ គឺជាបញ្ហាប្រឈមដ៏ធំមួយ។ SDGs រួមបញ្ចូលការដោះស្រាយបញ្ហាវិសមភាពជាបន្តបន្ទាប់ ដើម្បីសម្រេចបាននូវការមានទឹកប្រើប្រាស់ជាសកលនៅត្រឹមឆ្នាំ ២០៣០ ហើយក៏ប្រាថ្នាចង់បានកំរិតខ្ពស់ជាងសេវាមូលដ្ឋានផងដែរពោលគឺការគ្រប់គ្រងអនាម័យ និងការផ្គត់ផ្គង់ទឹកស្អាតដែលកាន់តែមានប្រសិទ្ធភាព។ ទឹកដែលបានផ្តល់ដោយសុវត្ថិភាពតាមប្រព័ន្ធបំពង់ទឹកមានលក្ខណៈស្រដៀងគ្នាបំផុតទៅនឹងនិយមន័យ SDG ស្តីពីការគ្រប់គ្រងសេវាទឹកប្រកបដោយសុវត្ថិភាព។ ការបង្កើនលទ្ធភាពទទួលបានទឹកមានសុវត្ថិភាពតាមប្រព័ន្ធបំពង់ទឹកនឹងជួយឱ្យកម្ពុជារីកចម្រើនលឿនឆ្ពោះទៅរកគោលដៅរបស់ SDG ។ ផលប៉ះពាល់នៃការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័សត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យធនធានទឹកកាន់តែខ្សត់ កាន់តែកខ្វក់ និងពិបាកព្យាករណ៍។ ក្នុងន័យនេះ ការគ្រប់គ្រងទឹកសំអុយពីតំបន់ដែលមានប្រជាជនរស់នៅច្រើន បន្ថែមលើការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពចំពោះប្រជាជន អាចកាត់បន្ថយការបំពុលដល់ប្រភពទឹកនិងបរិស្ថានបាន។

# ២. គោលបំណងនៃក្របខ័ណ្ឌ

២. គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោក ៤.១០ ស្តីពីជនជាតិដើមភាគតិចជម្រុញឱ្យមានគម្រោងនេះដោយសារតែមានជនជាតិដើមនៅក្នុងតំបន់អនុវត្តគម្រោង។ ដោយអនុលោមតាម OP ៤.១០ និងមុនដំណាក់កាលវាយតម្លៃ គម្រោងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPPF) ត្រូវបានបង្កើតឡើង ដើម្បីធានាថាជនជាតិដើមភាគតិចនឹងត្រូវបានពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ និងប្រកបដោយអត្ថន័យនាំទៅដល់ការពិគ្រោះយោបល់ដោយសេរី និងជូនដំណឹងជាមុន (FPIC) ថាពួកគេនឹងមានឱកាសស្មើគ្នាក្នុងការចែករំលែកអត្ថប្រយោជន៍នៃគម្រោង ហើយថាផលប៉ះពាល់អវិជ្ជមានដែលមានសក្តានុពលត្រូវបានកាត់បន្ថយឱ្យបានត្រឹមត្រូវ។ IPPF នឹងបង្កើតជាមូលដ្ឋានសម្រាប់ការអនុវត្តគម្រោង និងតាមដាន និងវាយតម្លៃអំពីរបៀបដោះស្រាយរបស់គម្រោងជាមួយបញ្ហាជនជាតិដើមភាគតិច។ នៅដំណាក់កាលអនុវត្តន៍គម្រោង ផែនការប្រជាជន ជនជាតិដើមភាគតិច (IPP) នឹងត្រូវបានបង្កើតឡើងផ្អែកលើ IPPF នេះ បន្ទាប់ពីតំបន់គោលដៅត្រូវបានកំណត់យ៉ាងច្បាស់លាស់ ហើយលទ្ធផលនៃការត្រួតពិនិត្យប្រព័ន្ធសង្គមបានបញ្ជាក់ពីផលប៉ះពាល់អវិជ្ជមានមកលើសហគមន៍ជនជាតិដើមភាគតិច។

# ៣. ការពិពណ៌នាអំពីគម្រោង

៣. គោលបំណងអភិវឌ្ឍន៍គម្រោង (PDO) គឺដើម្បីបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាត សេវាកម្មអនាម័យ និងពង្រឹងដំណើរការប្រតិបត្តិរបស់អ្នកផ្តល់សេវាកម្មនៅតាមទីក្រុង ឬតំបន់ដែលបានជ្រើសរើស។

៤. **គម្រោងដែលបានស្នើមានសមាសភាគពីរគឺ** (១) គាំទ្រដល់ការផ្គត់ផ្គង់ទឹកនៅតាមខេត្ត នៅតាមក្រុង និងឃុំមួយចំនួន (ii) គាំទ្រការលើកកម្ពស់ប្រព័ន្ធអនាម័យខេត្តនៅខេត្តសៀមរាបនិងតំបន់ផ្សេងទៀត។ សមាសភាគនីមួយៗត្រូវបានបែងចែកបន្តទៅជាអនុសមាសភាគវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងអនុសមាសភាគអនុវត្តការពង្រឹងស្ថាប័ន អនុវត្តគោលនយោបាយ និងអនុវត្តគម្រោង។

## សមាសភាគទី ១: ការផ្គត់ផ្គង់ទឹកនៅថ្នាក់ខេត្ត (IDA-៣០.៥ លានដុល្លារអាមេរិក)

៥. សមាសភាគនេះ ផ្តោតលើការគាំទ្រដល់ការពង្រីកសេវាផ្គត់ផ្គង់ទឹកទៅកាន់តំបន់ទីប្រជុំជនមួយចំនួន។ គម្រោងនេះនឹងជួយដល់អ្នកផ្គត់ផ្គង់សេវាទឹកស្អាតសាធារណៈនៅថ្នាក់ខេត្តនៅតាមទីរួមខេត្តមួយចំនួន ដើម្បីបន្ថែម និងពង្រីកបណ្តាញចែកចាយទឹកបម្រើឱ្យអតិថិជនបន្ថែមទៀត (រួមទាំងការកសាងកន្លែងផលិតទឹកបន្ថែម តាមការចាំបាច់)។ សមាសភាគនេះក៏គាំទ្រដល់ការកសាងប្រព័ន្ធផ្គត់ផ្គង់ទឹកម៉ាស៊ីនខ្នាតតូចនៅតាមបណ្តាឃុំមួយចំនួននៅក្រៅទីរួមខេត្តសំខាន់ៗ ដែលនៅមិនទាន់សេវាកម្មនៅឡើយ ប៉ុន្តែប្រជាពលរដ្ឋមានចំនួន និងដង់ស៊ីតេសមស្របសម្រាប់ការផ្គត់ផ្គង់ទឹកម៉ាស៊ីន។ ការផ្តល់ហិរញ្ញប្បទាននិងប្រតិបត្តិការរបស់វិស័យឯកជននៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូចនឹងត្រូវបានពិនិត្យមើល និងជំរុញតាមរយៈលទ្ធភាពបច្ចេកទេស សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គម្រោងនេះនឹងជួយអភិវឌ្ឍន៍យន្តការមួយ ដើម្បីពិនិត្យមើលប្រព័ន្ធផ្គត់ផ្គង់ទឹកខ្នាតតូចដែលបានស្នើសុំនៅតាមបណ្តាឃុំនានាពិចារណាលើជម្រើសសម្រាប់ការផ្តល់ហិរញ្ញប្បទានរបស់ឯកជន និង / ឬសាធារណៈ ប្រតិបត្តិការ និងការគ្រប់គ្រងហើយបន្ទាប់មកដើម្បីរចនាគម្រោងឱ្យបានសមស្រប។ គេរំពឹងថាកម្មវិធីវិកិលនៃការគាំទ្រចំពោះការរៀបចំ និងការវិនិយោគចំពោះគម្រោងផ្គត់ផ្គង់ទឹកនឹងត្រូវបានអនុវត្ត។ ការវិនិយោគនឹងចាប់ផ្តើមពីកម្មវិធីអាទិភាពបឋមដែលត្រូវបានរៀបចំឡើងក្នុងអំឡុងពេលរៀបចំគម្រោង ដើម្បីសាកល្បងនិងត្រួសត្រាយផ្លូវសម្រាប់កម្មវិធីវិនិយោគទុនវិកិលមួយដោយរលូន។ ជំនួយបច្ចេកទេសដើម្បីកំណត់ វាយតម្លៃ និងរៀបចំបន្ថែមនូវកម្មវិធីទីក្រុង និងឃុំដែលបានជ្រើសរើស នឹងចាប់ផ្តើមស្របគ្នា។ ដោយសារតែបញ្ហាសន្តិសុខ និងនិរន្តភាពទឹកទាក់ទងទៅនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ ការរចនាដ៏ល្អប្រសើរសម្រាប់ប្រសិទ្ធភាពថាមពលតាមរយៈការកំណត់ទំហំបរិមាណគ្រឿងបរិក្ខារអគ្គិសនី និងគ្រឿងចក្រសមស្រប តម្រូវឱ្យមានការគ្រប់គ្រងការអភិរក្សទឹក ការអភិវឌ្ឍប្រភពទឹកដទៃទៀត និងមានការការពារប្រភព និងនិរន្តរភាព។

៦. ជំនួយបច្ចេកទេសនឹងត្រូវផ្តល់ដើម្បីបន្ថែម និងគាំទ្រដល់ការគ្រប់គ្រងគម្រោង និងសមត្ថភាពត្រួតពិនិត្យរបស់ទីភ្នាក់ងារអនុវត្ត។ លើសពីនេះទៀត សមាសភាគនេះក៏នឹងរួមបញ្ចូលផងដែរនូវជំនួយបច្ចេកទេសដើម្បីលើកកម្ពស់លទ្ធផលអនុវត្តន៍សម្រាប់អ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកថ្នាក់ខេត្តដែលបានជ្រើសរើសសំដៅគ្រប់គ្រង និងដំណើរការប្រព័ន្ធទាំងនេះ ឱ្យជានាបាននូវនិរន្តរភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ រួមបញ្ចូលការពិចារណាអំពីហានិភ័យនៃការប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធសង្កេតនិងវាស់ស្ទង់ (O&M) របស់ប្រព័ន្ធនេះ និងដើម្បីធានាភាពតំណាងយេនឌ័រក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក។ សមាសភាគនេះនឹងផ្តល់ជំនួយបច្ចេកទេសដើម្បីសិក្សា ណែនាំ និងបង្កើតកម្មវិធីតបណ្តាញទឹក (រាប់បញ្ចូលទាំងកម្មវិធីផ្អែកលើលទ្ធផលតាមការចាំបាច់) ដែលផ្តោតលើការជួយដល់គ្រួសារក្រីក្រដែលមានបញ្ហាផ្នែកអាហារូបត្ថម្ភ (ឧទាហរណ៍ គ្រួសារដែលមានកុមារអាយុក្រោម ៥ ឆ្នាំ) ដើម្បីទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត។ កម្មវិធីនៃការប្រាស្រ័យទាក់ទងផ្នែកអាហាររូបត្ថម្ភនិងការលើកកម្ពស់ការគ្រប់គ្រង / ការសំអាតទឹក និងឥរិយាបថស្តីពីអនាម័យខ្លួនប្រាណផ្សេងទៀត នឹងត្រូវបានអនុវត្ត។ សារទាំងអស់នឹងត្រូវបានជូនដំណឹងតាមរយៈការវិភាគយេនឌ័រដើម្បីបង្កើនអត្ថប្រយោជន៍របស់ស្ត្រីនិងក្មេងស្រី។ កម្មវិធីប្រាស្រ័យទាក់ទងនេះនឹងព្យាយាមសហការ និងសម្របសម្រួលជាមួយកម្មវិធីប្រាស្រ័យទាក់ទងនឹងអាហារូបត្ថម្ភ និងជំងឺក្រិនដទៃទៀត ដូចជាការលើកកម្ពស់ និងពង្រឹងការបញ្ជូនសារសុខភាព អាហារូបត្ថម្ភ និងអនាម័យខ្លួនប្រាណនៅតាមទីប្រជុំជននិងឃុំនានា។ នៅទីកន្លែងដែលគម្រោងប្រសព្វគ្នាជាមួយសំណើគម្រោងអាហារូបត្ថម្ភកម្ពុជា (បច្ចុប្បន្នកំពុងរៀបចំ) សកម្មភាពរួមគ្នា នឹងប្រព្រឹត្តទៅតាមរយៈការជំរុញវេទិកាចែកចាយទូទៅ និងការតាមដានអ្នកទទួលផលដែលទទួលអន្តរាគមន៍រួមគ្នា។ ជំនួយបច្ចេកទេសមួយដើម្បីគាំទ្រដល់ក្រសួងឧស្សាហកម្មនិងសិប្បកម្មក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រផ្គត់ផ្គង់ទឹកនៅទីក្រុងនិងផែនការវិនិយោគក៏ត្រូវបានផ្តល់ជូនផងដែរ។

## សមាសភាគទី ២: ការកែលើកកម្ពស់ប្រព័ន្ធអនាម័យក្រុងសៀមរាបនិងតំបន់ផ្សេងៗទៀត (IDA – ២៤.៥ លានដុល្លារអាមេរិក)

៧. សមាសភាគនេះផ្តោតលើការគាំទ្រដល់ការអភិវឌ្ឍ និងការសាងសង់បណ្តាញលូទឹកសំអុយធំទៅកាន់បំពង់លូចែកចាយចំបងដែលមានស្រាប់នៅក្រុងសៀមរាប ដើម្បីឱ្យគ្រួសារ និងក្រុមហ៊ុនអាចតភ្ជាប់ដោយផ្ទាល់ទៅនឹងប្រព័ន្ធលូបង្ហូររបស់ក្រុង។ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតខ្នាតធំនិងខ្សែបញ្ជូនចម្បងត្រូវបានសាងសង់ឡើងនៅឆ្នាំ ២០០៨ ដោយគ្មានលូវង និងលូជើងក្អែបឡើយ។ បច្ចុប្បន្ននេះមានតែសំណង់ធំៗនៅក្បែរទឹកធំ ១ ប៉ុណ្ណោះដែលត្រូវបានតភ្ជាប់ហើយត្រូវពឹងផ្អែកលើលូស្តុកសម្រាប់ស្តុកទឹកសំអុយចេញពីបំពង់មេ។ សមត្ថភាពស្តុកតិចតួចនិងការខូចខាតចំពោះបំពង់លូបញ្ជូនធ្វើឱ្យទឹកសំអុយតិចតួចប៉ុណ្ណោះដែលហូរទៅដល់រោងចក្រប្រព្រឹត្តិកម្ម។ នៅកន្លែងដែលការផ្លាស់ប្តូរអាកាសធាតុដែលបណ្តាលឱ្យមានទឹកជំនន់នៅក្នុងទីក្រុង មានការចម្លងរោគយ៉ាងខ្លាំងពីជំនន់ទឹកលាមកបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពនៅតាមតំបន់ជាច្រើនក្នុងទីក្រុង។ ការសាងសង់បណ្តាញលូទឹកសំអុយធំជាមួយកម្មវិធីតភ្ជាប់គ្រួសារនឹងធ្វើឱ្យប្រសើរឡើងនូវការប្រមូល និងការបញ្ជូនលាមកគ្រួសារទៅកាន់កន្លែងប្រមូលនិងកន្លែងសម្អាតដែលកាត់បន្ថយការចម្លងរោគពីលាមកទៅកាន់ប្រជាជនក្នុងករណីមានទឹកជំនន់។ សមាសភាគនេះក៏គាំទ្រការស្តារនីតិសម្បទា និងការបង្កើនបន្ថែមនូវប្រព័ន្ធលូទឹកសំអុយដែលមានស្រាប់ដើម្បីលើកកម្ពស់ប្រសិទ្ធ

ភាពដំណើរការរបស់ប្រព័ន្ធលូ រួមជាមួយការស្តារឡើងវិញ និងការធ្វើឱ្យ ប្រសើរឡើងនូវស្ថានីយ៍បូមលូ និងប្រព័ន្ធទទួល និងគ្រប់គ្រងភក់។

៨. សមាសភាគនេះនឹងជួយដល់ការគាំទ្រការលើកកម្ពស់អនាម័យបរិស្ថាន និង / ឬការវិនិយោគនៅតាមបណ្តាឃុំដែលការផ្គត់ផ្គង់ទឹកស្ថិតក្រោមការគាំទ្រនៃសមាសភាគទី ១ ដើម្បីដោះស្រាយបញ្ហាទឹកសំអុយដែលបានមកពីការកើនឡើងនៃការផ្គត់ផ្គង់ទឹក។ ដោយសារគម្រោងផ្គត់ផ្គង់ទឹកស្អាតទាំងនេះមានទំហំតូច ការយកចិត្តទុកដាក់ទំនងជាផ្តោតលើការលើកកម្ពស់អនាម័យបរិស្ថាន គ្រួសារ និងការបង្ហូរទឹកសំអុយបានល្អនៅជុំវិញគ្រួសារ។ តាមដែលអាចអនុវត្តបាន ប្រព័ន្ធសំអាតទឹកសំអុយខ្នាតតូចនឹងត្រូវបានបង្កើតឡើង។

៩. ជំនួយបច្ចេកទេសនឹងត្រូវផ្តល់ដើម្បីបន្ថែម និងគាំទ្រដល់ការគ្រប់គ្រងគម្រោង និងសមត្ថភាពត្រួតពិនិត្យរបស់ភ្នាក់ងារអនុវត្ត។ លើសពីនេះទៅទៀត សមាសភាគនេះក៏រួមបញ្ចូលផងដែរនូវជំនួយបច្ចេកទេសលើកកម្ពស់សមត្ថភាពបច្ចេកទេស និងលទ្ធផលអនុវត្តដល់រោងចក្រប្រព្រឹត្តកម្មទឹកសំអុយខេត្តសៀមរាប ដើម្បីឱ្យមានដំណើរការ និងការថែទាំឱ្យបានគ្រប់គ្រាន់នូវបណ្តាញលូបង្ហូរទឹកសំអុយ និងមូលដ្ឋានអនាម័យ ការគ្រប់គ្រងសេវាប្រមូលភក់លាមក រួមទាំងការការធ្វើប្រព្រឹត្តកម្មដើម្បីឱ្យទឹកសំអុយឆ្លើយតបនឹងស្តង់ដារបង្ហូរចេញ និងដើម្បីឱ្យមានភាពតំណាងយេនឌ័រកាន់តែប្រសើរឡើងក្នុងការគ្រប់គ្រងឧបករណ៍ប្រើប្រាស់។ ឧបករណ៍ចាំបាច់សម្រាប់ដំណើរការ និងថែទាំ កនឹងត្រូវផ្តល់ឱ្យផងដែរ។ កម្មវិធីស្តីពីការប្រាស្រ័យទាក់ទង (ត្រូវជូនដំណឹងដោយការវិភាគយេនឌ័រ) និងការលើកកម្ពស់នឹងត្រូវបានអនុវត្តដើម្បីលើកទឹកចិត្តដល់គ្រួសារ និងអាជីវកម្មនានា ក្នុងការភ្ជាប់ប្រព័ន្ធលូទឹកសំអុយ។ ជំនួយបច្ចេកទេសសម្រាប់គាំទ្រដល់ក្រសួងសាធារណៈការ និងដឹកជញ្ជូនក្នុងការធ្វើផែនការរៀបចំយុទ្ធសាស្ត្រអនាម័យទីក្រុង និងផែនការវិនិយោគក៏នឹងត្រូវផ្តល់ផងដែរ។

១០. **អ្នកទទួលផលពីគម្រោង៖** អ្នកទទួលផលផ្ទាល់គឺជាប្រជាជនទីក្រុង និងស្រុក ដែលគម្រោងផ្គត់ផ្គង់ទឹក និង / ឬអនាម័យ ដែលនឹងត្រូវផ្តល់ហិរញ្ញប្បទានដោយគម្រោងនេះ។ បច្ចុប្បន្ននេះការវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាតត្រូវបានរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាពលរដ្ឋ ១០៥.០០០ នាក់នៅតាមទីក្រុង និងឃុំនានា។ ក្នុងចំណោមប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់សេវានៃបណ្តាញអនាម័យតាមសហគមន៍ក្នុងខេត្តសៀមរាប ប្រជាជនប្រមាណជា ២២,០០០ នាក់ត្រូវបានរំពឹងថានឹងទទួលបានសេវាដែលមានគុណភាព និងសេវាអនាម័យខ្ពស់ តាមរយៈការតភ្ជាប់ទៅបណ្តាញលូ ឬការប្រមូល និងសំអាតភក់ដោយសុវត្ថិភាព។ អ្នកទទួលផលបន្ថែមទៀត រួមមាន អ្នកទទួលបានសារផ្លាស់ប្តូរឥរិយាបថអនាម័យនៅក្នុងទីតាំងអនុវត្តគម្រោង និងក្រៅពីនេះ បុគ្គលិក ( ទាំងបុរសនិងស្ត្រី) នៃប្រតិបត្តិករផ្គត់ផ្គង់ទឹកនិងអនាម័យ ដែលទទួលបានការគាំទ្រលើការកសាងសមត្ថភាពពីគម្រោង។

១១. **ការចូលរួមរបស់ប្រជាពលរដ្ឋនឹងត្រូវអនុវត្តន៍នៅក្នុងគម្រោងទាំងមូល៖** ក្នុងអំឡុងពេលការអនុវត្តគម្រោងវេទិកាសាធារណៈរបស់រាជរដ្ឋាភិបាលនៅទីកន្លែងដែលកើតមានក្តីបារម្ភនោះ ត្រូវអនុវត្តន៍បន្តជានិច្ចដើម្បីឆ្លៀតឱ

កាសផ្តល់ព័ត៌មានអំពីគម្រោងឱ្យបានច្រើនទៅកាន់ប្រជាពលរដ្ឋ និងដើម្បីទទួលបានសំណូមពរសម្រាប់គម្រោង។ ប្រតិបត្តិករទឹកស្អាត និងប្រតិបត្តិករស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ដែលទទួលបានការគាំទ្រពីគម្រោងនេះក៏នឹងអនុវត្តន៍ក្របខ័ណ្ឌគណនេយ្យភាពសង្គមតាមរយៈការចូលរួមពីប្រជាពលរដ្ឋ ដែលទទួលបានផលប្រយោជន៍ពីសេវាកម្មៈ (ក) យល់ដឹងពីបទដ្ឋានសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យក្នុងកម្រិតអប្បបរ (ខ) តាមដាន និងផ្តល់យោបល់ត្រឡប់ពីសេវាប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាត និង (គ) កំណត់ និងឯកភាពលើសកម្មភាពដែលអ្នកផ្តល់សេវាយកទៅប្រតិបត្តិ ដើម្បីកែលម្អគុណភាពនៃសេវាកម្ម។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏មានយន្តការបណ្តឹងមួយសម្រាប់សាធារណជនដាក់ពាក្យបណ្តឹងទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងតាមដានពីរបៀបដោះស្រាយពាក្យបណ្តឹងទាក់ទិននឹងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនោះ។ គម្រោងនេះក៏នឹងបង្កើនអានុភាពលើវេទិកានេះផងដែរ តាមរយៈការផ្សព្វផ្សាយយន្តការនេះឱ្យសាធារណជនដឹងកាន់តែទូលំទូលាយ និងដោយគាំទ្រដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដោះស្រាយបណ្តឹងឱ្យទាន់ពេលវេលា។

## ៤. ទិដ្ឋភាពទូទៅនៃប្រជាជនជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា

១២. នៅក្នុងច្បាប់ និងគោលនយោបាយនានា រដ្ឋាភិបាលកម្ពុជាបានចែង ជនជាតិដើមថាជា"ជនជាតិដើមភាគតិច" ។ ជនជាតិដើមភាគតិចត្រូវបានគេស្គាល់ដាច់ដោយឡែកពីក្រុមជនជាតិនានា ដូចជា ជនជាតិឡាវ ដែលរស់នៅភាគឦសាន្តនៃប្រទេសកម្ពុជា ដែលជាទូទៅមិនត្រូវបានចាត់ទុកថាជា "ជនជាតិដើម" នោះទេ រីឯជនជាតិចាម ឬជនជាតិវៀតណាម ក៏មិនត្រូវបានចាត់ទុកថាជាជនជាតិដើមដែរ។ ទោះជាយ៉ាងណាក្តីទស្សនៈអំពីជនជាតិដើមភាគតិចពុំមានលក្ខណៈច្បាស់លាស់ឡើយ ហើយជនជាតិខ្មែរ (ក្រុមជនជាតិភាគច្រើន) រស់នៅក្នុងតំបន់មួយចំនួនមានលក្ខណៈជាច្រើន ជាជនជាតិដើមភាគតិច។

១៣. ក្នុងចំណោមប្រជាជនកម្ពុជាទាំងអស់ មាន៩០ ភាគរយទៅ ៩៥ ភាគរយជាជនជាតិខ្មែរ។ ចំនួន ៥-១០ ភាគរយផ្សេងទៀត រួមមាន ជនជាតិភាគតិចដូចជា ចាមមូស្លីម ចិន និងវៀតណាម និងក្រុមជនជាតិដើមភាគតិចចំនួនដប់ប្រាំពីរដែលគេហៅថា "ខ្មែរលើ" ឬ "កុលសម្ព័ន្ធភ្នំ" ជាជនជាតិភាគតិចមិនមែនខ្មែរ។ ក្រុមទាំងនេះត្រូវបានប៉ាន់ស្មានថាមានចំនួនប្រហែល ១២០.០០០ នាក់ និងប្រមាណជា ១% នៃចំនួនប្រជាជនកម្ពុជាសរុប។ ក្រុមជនជាតិដើមភាគតិចទាំងដប់ប្រាំពីរ មានចាប់ពី ៣០០ នាក់ទៅ ១៩០០០ នាក់រួមមាន ព្នង គួយ មិល ក្រោល ថ្មន ខោញ ទំពួន ចារ៉ាយ គ្រឹង កាវែត ស្អូច លុន កាចក់ ព្រៅ សួយ (សាអុង)ស្ទៀង, និង កាវែត ។ ក្រុមជនជាតិដើមភាគតិចភាគច្រើនរស់នៅខេត្តរតនគិរី (៦៧,៩ ភាគរយ) និងមណ្ឌលគិរី (៥៩,៣ ភាគរយ) ។ ស្ទឹងត្រែង និងក្រចេះក៏មានចំនួនក្រុមជនជាតិដើមភាគច្រើនរស់នៅផងដែរ។

១៤. នៅមណ្ឌលគិរីមាន ១៣,២៥៧ គ្រួសារ មានប្រជាជនសរុបចំនួន ៦២,២១៨ នាក់ (NCDD ២០១០) ។ ក្នុងនោះ ៧០,៧០ ភាគរយតំណាងក្រុមជនជាតិដើមភាគតិចចំនួន ៩ និងក្រុមជនជាតិភាគតិចចំនួន ៣ គឺ ព្នង

(៣៦,៩៩២ នាក់ស្មើនឹង ៥៩,៤៦ ភាគរយ នៃចំនួនប្រជាជនសរុបនៅក្នុងខេត្ត) គួយ (២៣ នាក់ ស្មើនឹង ០,០៤ ភាគរយ) ស្ទៀង (៤៩២) (ស្មើនឹង ០,៧៩%) មីល (៣៥៥ នាក់ស្មើនឹង ០,៥៧%) ក្រោល (១០៨១ នាក់ស្មើនឹង ១,៧៤%) ថ្មូន (៤៩ នាក់ស្មើនឹង ០,០៨%) ទំពួន (៣២ នាក់ស្មើនឹង ០,០៥% ), ជនជាតិភាគតិច (២២៥ នាក់ស្មើនឹង ០,៣៦%), គ្រឹង (៨០ នាក់ស្មើនឹង ០,១៣%) និងក្រុមជនជាតិភាគតិចផ្សេងទៀតគឺខ្មែរឥស្លាម (ស្មើនឹង ៣,៤៥៥ នាក់ស្មើនឹង ៥,៥៤%) វៀតណាម (៨៧ នាក់ស្មើនឹង ០,១៣%) និងឡាវ (១.១៣០ នាក់ស្មើនឹង ១.៨២ ភាគរយ) ។

១៥. ទាក់ទងនឹងទំនាក់ទំនងជនជាតិភាគតិច ប្រជាជនកម្ពុជានៅខេត្តមណ្ឌលគិរីចាត់ទុកខ្លួនគេថាជាអ្នកលើ (អ្នករស់នៅតំបន់ខ្ពង់រាប) សំដៅដល់ប្រជាជនដែលរស់នៅតំបន់កសិកម្ម និងធ្វើស្រែ និងដំណាំសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬសំរាប់លក់ ។ កុលសម្ព័ន្ធភ្នំ ឬខ្មែរលើដែលគេស្គាល់ជាទូទៅ រស់ប្រមូលផ្តុំនៅតំបន់ភ្នំភាគឦសាននៃប្រទេសកម្ពុជា។.

**រូបភាពទី ១: ជនជាតិដើមភាគតិចនិងផែនទីជនជាតិភាគតិច**



Scanned by CamScanner

*ប្រភព: ផ្ទាំងរូបភាពអង្គការយូណេស្កូស្តីពីក្រុមភាសាជនជាតិភាគតិចនៅកម្ពុជា ខែធ្នូឆ្នាំ*២០១១

## តារាងទី ១: ក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច

**Estimated EGIDS values for languages in Cambodia**

| Name (English) | Name (Khmer) | Population | Primary Location | EGIDS | Khmer Orthography | Bilingual Education |
|---|---|---|---|---|---|---|
| Cham [cja] | ចាម | 204,080 | Multiple | 6a | none | none |
| Kuy, Kui [kdt] | កួយ | 28,612 | Preah Vihear | 7 | Yes, INL recognized | pilot NFE |
| Bunong, Phnong [cmo] | ព្នង | 37,507 | Mondulkiri | 5 | Yes, INL recognized MOEYS approved | NFE, pilot FE |
| Tampuan [tpu] | ទំពួន | 31,013 | Ratanakiri | 6b | Yes, INL recognized MOEYS approved | NFE, pilot FE |
| Jarai [jra] | ចារ៉ាយ | 26,335 | Ratanakiri | 5 | In process | none |
| Kreung (Brao Tanap) [krr] | គ្រឹង | 18,214 | Ratanakiri | 6a | Yes, INL recognized MOEYS approved | NFE, pilot FE |
| Brao Ombaa [brb] | ព្រៅ | 7,027 | Ratanakiri | 6a | Yes, INL recognized MOEYS approved | NFE |
| Brao Kavet [krv] | កាវែត | 5,258 | Stung Treng / Ratanakiri | 6a | Yes, INL recognized MOEYS approved | NFE, pilot FE |
| Kachok [xkk] | កាចក់ | 3,365 | Ratanakiri | 6b | none | none |
| Stieng [sti] | ស្ទៀង | 6,541 | Kratie | 6b | none | none |
| Kraol [rka] | ក្រោល | 4,202 | Kratie | 6b | none | none |
| Mel | មិល (កាច្រក) | 1,697 | Kratie | 8b | none | none |
| Thmoan | ថ្មូន | 865 | Kratie | 7 | none | none |
| Khaonh | ខោញ | 743 | Kratie | 8b | none | none |
| Somray [smu] | សំរ៉ាយ | 4,100 | Pursat | 8b | none | none |
| Pear [pcb] | ព័រ | 1,674 | Preah Vihear | 8a | none | none |
| Sa'ong (Suoy) | សាអុង (សូយ) | 857 | Kampong Speu | 7 | none | none |
| Ch'ung (Saoch) [scq] | ស្អូច | 445 | Kampong Som | 8b | none | none |
| Lao [lao] | ឡាវ | 18,515 | Stung Treng | 6b | none | none |
| Vietnamese [vie] | វៀតណាម | 72,775 | Multiple | 4 | none | private |
| Hakka [hak] | ចិនខិ (ហាក់កា) | 5,000 | Multiple | 6b | none | none (private Mandarin) |
| Cantonese [yue] | ចិនកន្តាំង | 55,000 | Multiple | 6b | none | none (private Mandarin) |
| Hokkien [nan] | ចិនហុកកៀន | 5,000 | Multiple | 6b | none | none (private Mandarin) |
| Teochiu [nan] | ចិនទាជីវ | 440,000 | Multiple | 6b | none | none (private Mandarin) |
| Hainanese [nan] | ចិនហៃណាំ | 15,000 | Multiple | 6b | none | none (private Mandarin) |

*ប្រភព: ផ្ទាំងរូបភាពអង្គការយូណេស្កូស្តីពីក្រុមភាសាជនជាតិភាគតិចនៅកម្ពុជា ខែធ្នូឆ្នាំ២០១១*

តារាងទី ២: វត្តមានជនជាតិដើមភាគតិចនៅកម្ពុជានៅតាមបណ្តាខេត្ត (២០០៦)

| លរ | ជាតិពិន្ទុ | រ.គិរី | ម.គិរី | ក្រចេះ | ព្រះវិហារ | កំពង់ធំ | ស្ទឹងត្រែង | ឧមជ | កំពង់ចាម | ពោធិសាត់ | កំពង់ស្ពឺ | បមជ | បប | កពសហន | សៀមរាប | កោះកុង | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | គួយ | | | ៥,៩៣ | ១៦,៧ | ១៣,០ | ១,៦៤ | ២,២០ | | | | ១,៧១ | ៨ | | | | ៤១,២ |
| ២ | ព្នង | ២៦៧ | ២៦,៨ | ១២,៤ | ២៤ | | ៤៣០ | ៦៩៩ | | | | | ៣ | | | | ៤០,៧ |
| ៣ | ទំពួន | ៣១,០ | ៣៨៨ | | ៥ | | ៤ | ២៨១ | | | | | ១៦ | | | | ៣១,៧ |
| ៤ | ចារ៉ាយ | ២០,១ | ៨៤ | | | | ១២ | ១៥៨ | | | | | ១៤ | | | | ២០,៤ |
| ៥ | គ្រឹង | ១៨,៤ | ៥៧ | | | | ២៧៨ | ១២៤ | | | | | | | | | ១៨,៩ |
| ៦ | ស្ទៀង | | ៦៤៨ | ១០,៥ | | | | ២៧ | ២,៥៦ | | | | | | | | ១៣,៨ |
| ៧ | ព្រៅ | ៧,៩៦ | | | | | ៤៤៤ | | | | | | | | | | ៨,៤១ |
| ៨ | កាវែត | ២,៣ | | | | | ២,៧១ | ១៨ | | | | | | | | | ៥,១០ |
| ៩ | ក្រោល | | ៦៥៩ | ៣,៤១ | | | | ២៩ | | | | | | | | | ៤,០៩ |
| ១០ | មិល | | | ៣,១៧ | | | | | | | | | | | | | ៣,១៧ |
| ១១ | កាចក់ | ២,៨៨ | | | | | ១ | ៥២ | | | | | | | | | ២,៩៤ |
| ១២ | ព័រ | | | | ១,៣២ | | | | | ១,២០ | | | | | | | ២,៥៣ |
| ១៣ | ខោញ | | | ១,៥២ | | | | | | | | | ៤៣៣ | | | | ១,៩៦ |
| ១៤ | ចុង(សាអុង?) | | | | | | | | | ៧៧៤ | | | | | | ១,០៦ | ១,៨៣ |
| ១៥ | សូយ | | | | | | | | | | ១,៨៣ | | | | | | ១,៨៣ |
| ១៦ | ថ្មូន | | ១៤៨ | ៤៤៨ | | | | ៥ | | | | | | | | | ៦០១ |
| ១៧ | លន | ២៨៩ | | | | | ២៥១ | | | | | | | | | | ៥៤០ |
| ១៨ | ស្អូច | | | | | | | | | | | | | ១០៦ | | | ១០៦ |
| ១៩ | រដែ | ២ | | | | | | ១៦ | | | | | | | | | ១៨ |
| ២០ | កែក | | | | | | | ១៥ | | | | | | | | | ១៥ |
| ២១ | រអុង | | | | | | | | | | | | | | | | ០ |
| ២២ | ស្នូង | | | | | | | | | | | | | | | | ០ |
| ២៣ | ល្មើន | | | | | | | | | | | | | | | | ០ |
| ២៤ | សំរែ | | | | | | | | | | | | | | | | ០ |
| សរុប | | ៨៣,៤៩២ | ២៨,៨៥០ | ៣៧,៥៤៦ | ១៨,០៨៩ | ១៣,០៤៤ | ៥,៧៧៤ | ៣,៦២៧ | ២,៥៦៤ | ១,៩៨១ | ១,៨៣៣ | ១,៧១២ | ៤៧៤ | ១០៦ | ០ | ១,០៦៤ | ២០០,១៥៦ |

ប្រភព: នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច

# ៥. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

## ៥.១ គោលនយោបាយ ច្បាប់ វិធាន និងបទប្បញ្ញត្តិ របស់ប្រទេសកម្ពុជាអនុវត្តចំពោះជនជាតិដើមភាគតិច

១៦. **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច:** គោលនយោបាយនេះត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែមេសាឆ្នាំ ២០០៩ និងដាក់ចេញនូវគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងជនជាតិដើមភាគតិចក្នុងវិស័យវប្បធម៌ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខភាព បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។ រួមជាមួយច្បាប់ភូមិបាល (ឆ្នាំ ២០០១) គោលនយោបាយនេះផ្តល់នូវការទទួលស្គាល់ចំពោះសិទ្ធិជនជាតិដើមភាគតិចចំពោះដីព្រៃឈើ វប្បធម៌ និងព្រៃឈើ។

១៧. **គោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់របស់សហគមន៍ជនជាតិដើមនៅកម្ពុជា**ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែមេសាឆ្នាំ ២០០៩ ហើយអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៩ ខែមិថុនាឆ្នាំ ២០០៩ ដោយ នាយករដ្ឋមន្ត្រី។ គោលនយោបាយនេះជាមូលដ្ឋាននៃការទទួលស្គាល់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ នូវសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការកាន់កាប់ និងប្រើប្រាស់ដីជាកម្មសិទ្ធិសមូហភាពរបស់ពួកគាត់។ គោលនយោបាយចែងថា ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព គឺខុសគ្នាពីការចុះបញ្ជីដីឯកជនរបស់បុគ្គលម្នាក់ៗ ដោយសារតែការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច គឺជាការចុះបញ្ជីក្បាលដីទាំងអស់ដែលជាកម្មសិទ្ធិរបស់សហគមន៍ទាំងមូលដែលរួមមានទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ស្របតាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២២៩ នៃច្បាប់ភូមិបាល និងអនុក្រឹត្យពាក់ព័ន្ធ។ ក្បាលដីទាំងនេះមានទំហំខុសៗគ្នាហើយអាចស្ថិតនៅក្នុងឃុំ / សង្កាត់តែមួយ ឬផ្សេងគ្នា។ ដូចនេះ ការចុះបញ្ជីក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចតម្រូវឱ្យមានអនុក្រឹត្យដោយឡែកដែលបន្ថែមលើនីតិវិធីដែលមានស្រាប់នៃការចុះបញ្ជីដីធ្លីដាច់ដោយដុំ និងការចុះបញ្ជីលក្ខណៈជាប្រព័ន្ធ។.

១៨. **រដ្ឋធម្មនុញ្ញកម្ពុជា (ឆ្នាំ** ១៩៩៣) គាំទ្រសិទ្ធិក្នុងការទទួលបានការអប់រំ ការអប់រំសម្រាប់ទាំងអស់គ្នា និងការអប់រំមូលដ្ឋាន ៩ ឆ្នាំ (មាត្រា ៦៥,៦៦,៦៧ និង ៦៨) ។ មាត្រា ៤៨ ចែងថា "រដ្ឋត្រូវការពារសិទ្ធិរបស់កុមារដូចមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេស សិទ្ធិរស់រានមានជីវិតការអប់រំ ការការពារ ក្នុងអំឡុងពេលសង្គ្រាម និងការកេងប្រវ័ញ្ចសេដ្ឋកិច្ច ឬការកេងប្រវ័ញ្ចផ្លូវភេទ" ។ មាត្រា ៤៦ ចែងថា "រដ្ឋនិងសង្គមត្រូវផ្តល់ឱកាសដល់ស្ត្រី ពិសេសស្ត្រីដែលរស់នៅតំបន់ជនបទដែលគ្មានការគាំទ្របានគ្រប់គ្រាន់ពីសង្គម ដើម្បីឱ្យពួកគេបានទទួលការងារ ការថែទាំវេជ្ជសាស្ត្រ និងបញ្ជូនកូនទៅកាន់តំបន់(សាលារៀន?) មានជីវភាពសមរម្យនិងមានជីវភាពសមរម្យ"។ មាត្រា ៣១.២ ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិ សេរីភាព ករណីយកិច្ចដូចគ្នា ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ដើមកំណើតឋានៈសង្គម ធនធាននិងស្ថានភាពឯទៀតឡើយ "។ មាត្រា ៤៤ ធានានូវសិទ្ធិស្របច្បាប់ក្នុងការមានសិទ្ធិជាម្ចាស់ដីធ្លីដោយស្មើភាពគ្នាសំរាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ "បុគ្គលទាំងអស់ ជាបុគ្គល ឬជាសមូហភាពមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែនីតិបុគ្គលខ្មែរ និងពលរដ្ឋសញ្ជាតិខ្មែរប៉ុណ្ណោះដែលមានសិទ្ធិ**ជា**ម្ចាស់លើដីធ្លី "។

១៩. ច្បាប់ស្តីពីការអប់រំត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី **១៩** ខែតុលាឆ្នាំ **២០០៧** ។ គោលបំណងនៃច្បាប់នេះគឺដើម្បីអភិវឌ្ឍន៍ធនធានមនុស្សរបស់ជាតិតាមរយៈការផ្តល់ការអប់រំពេញមួយជីវិតដល់អ្នកសិក្សា ដើម្បីទទួលបានចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរសីលធម៌ល្អ ឥរិយាបទសីលធម៌ និងបុគ្គលិកលក្ខណៈល្អ ដើម្បីលើកទឹកចិត្តដល់អ្នកសិក្សាឱ្យចេះ ស្រឡាញ់ និងការពារអត្តសញ្ញាណ វប្បធម៌និងភាសាជាតិ។

២០. **ច្បាប់ភូមិបាលឆ្នាំ** ២០០១ ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាឱ្យមានកម្មសិទ្ធិលើអចលនទ្រព្យ - ដីធ្លីរបស់ពួកគេ - ដោយមានប័ណ្ណកម្មសិទ្ធិសមូហភាព។ មាត្រា **២៣** នៅក្នុងច្បាប់កំណត់ថា សហគមន៍ជនជាតិដើមភាគតិចគឺជា:

- ក្រុមមនុស្សដែលបង្ហាញពីឯកភាពជាតិពិន្ទុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច
- ជាអ្នកអនុវត្តការរស់នៅបែបប្រពៃណី និង
- ជាអ្នកដាំដុះដីធ្លីដែលពួកគេកាន់កាប់ទៅតាមវិធានទំនៀមទម្លាប់នៃការប្រើប្រាស់រួមគ្នា

២១. មាត្រា ២៥ ក្នុងច្បាប់ភូមិបានកំណត់ដីសហគមន៍ជនជាតិដើមភាគតិចថា: "ដីសហគមន៍ជនជាតិដើមភាគតិចជាដីដែលសហគមន៍និយាយថាបានបង្កើតលំនៅដ្ឋានរបស់ខ្លួននិងជាកន្លែងដែលពួកគេអនុវត្តកសិកម្មតាមបែបប្រពៃណីរបស់ពួកគេហើយដីទាំងនេះមិនត្រឹមតែជាដីដាំដុះតែប៉ុណ្ណោះទេ" ក៏រួមបញ្ចូលទាំងការបំរុងទុកចាំបាច់សម្រាប់ការដាំដុះវិលជុំដែលត្រូវបានទាមទារដោយវិធីសាស្ត្រកសិកម្មដែលពួកគេកំពុងអនុវត្ត "។ មាត្រា ២៥ ចែងថា "ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិចនឹងត្រូវបានកំណត់តាមស្ថានភាពជាក់ស្តែងដែលបានអះអាងដោយសហគមន៍ដោយមានការយល់ព្រមពីអ្នកជិតខាង" ។ មាត្រា ២៦ ចែងថា "ភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុដែលមានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋដល់សហគមន៍ជនជាតិដើមភាគតិចជាទ្រព្យសមូហភាព។ ទ្រព្យសម្បត្តិសមូហភាពនេះរួមបញ្ចូលទាំងសិទ្ធិនិងការការពារកម្មសិទ្ធិទាំងអស់ដែលជាកម្មសិទ្ធិរបស់ម្ចាស់ឯកជនដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងឡាយណាដែលសហគមន៍ទាំងនោះបានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី" ហើយដីទាំងនោះពុំមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវដីបម្រុងដែលចាំបាច់ សម្រាប់ការធ្វើកសិកម្មពនេចរ ដែលចាំបាច់ចំពោះវិធីធ្វើកសិកម្មដែលពួកគេកំពុងអនុវត្ត។ មាត្រា ២៥ ក៏ចែងផងដែរថា "ការវាស់វែង និងកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចបានអះអាងដោយសហគមន៍ដោយមានការព្រមព្រៀងពីអ្នកជិតខាងរបស់ពួកគេ"។ មាត្រា ២៦ ចែងថា "កម្មសិទ្ធិនៃអចលនវត្ថុដែលមានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជាមួយសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពនេះរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចម្ចាស់កម្មសិទ្ធិឯកជនដែរ"។

២២. **ច្បាប់ស្តីពីព្រៃឈើឆ្នាំ** ២០០២ (មាត្រា **១១ ១៥ ១៦ ៤០**) ធានានិងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការបន្តការប្រើប្រាស់ និងការចូលទៅកាន់តំបន់ព្រៃមួយចំនួនដែលក្រុមទាំងនេះប្រើតាមបែបប្រពៃណី និងអនុវត្តវិធីរស់នៅរបស់ពួកគេក្នុងការទទួលផលពីព្រៃឈើ។

## ៥.២ កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា

២៣. កម្ពុជាគឺជាហត្ថលេខីលើឧបករណ៍អន្តរជាតិមួយចំនួនដែលការពារសិទ្ធិជនជាតិដើមភាគតិច ក៏ដូចជាអនុសញ្ញាស្តីពីជីវៈចម្រុះ (ឆ្នាំ ១៩៩២) ដលទទួលស្គាល់តួនាទីរបស់ជនជាតិដើមភាគតិចក្នុងការការពារជីវៈចម្រុះ។ នៅឆ្នាំ ១៩៩២ រដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ កតិកាសញ្ញានេះរួមបញ្ចូលទាំងសិទ្ធិក្នុងការដាំដុះដាក់លាក់ និងសិទ្ធិលើមធ្យោបាយចិញ្ចឹមជីវិត។ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

២៤. **សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច**ត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅខែកញ្ញាឆ្នាំ ២០០៧ ។ ប្រទេសជាច្រើនក្នុងពិភពលោករួមទាំងប្រទេសកម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាស ដែលមិនជាប់កាតព្វកិច្ចនេះ។

២៥. មាត្រា **៥** (e) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ធានាឱ្យមានភាពស្មើគ្នា និងគ្មានការរើសអើងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេសសិទ្ធិទទួលការអប់រំ និងការបណ្តុះបណ្តាល។ មាត្រា **១៣** នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) រួមបញ្ចូលទាំងបញ្ញត្តិស្តីពីការអប់រំបឋមសិក្សាដោយមិនគិតពីភេទ ជនពិន្ទុ ឬចំណុចណាមួយផ្សេងទៀត។ មាត្រា **១៣** បន្ថែមទៀតថារដ្ឋភាគីត្រូវធ្វើឱ្យមានការអប់រំមធ្យមសិក្សាទូទៅ និងអាចឱ្យសិស្សទាំងអសចូលរៀនបាន រួមទាំងតាមរយៈការបង្កើតឱ្យមានការអប់រំដោយឥតគិតថ្លៃជាបន្តបន្ទាប់ និងធ្វើការដើម្បីទទួលបានការអប់រំស្មើភាពគ្នានៅកម្រិតឧត្តមសិក្សា រួមទាំងតាមរយៈការផ្តល់ការអប់រំកម្រិតមធ្យមសិក្សាដោយឥតគិតថ្លៃ។ រដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នដល់ ICESCR ក្នុងឆ្នាំ **១៩៩២** ។

២៦. **អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (មាត្រា** ២៨ - **សិទ្ធិទទួលបានការអប់រំ)** បានផ្តល់សច្ចាប័នដោយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ **១៩៩២**: កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។ ការអប់រំបឋមសិក្សាមិនតម្រូវឱ្យបង់ថ្លៃ។ ត្រូវមានការអប់រំកម្រិតមធ្យមសិក្សាសំរាប់កុមារគ្រប់រូប។ វិន័យក្នុងតំបន់ត្រូវតែគោរពសេចក្តីថ្លៃថ្នូររបស់កុមារ។ បណ្តាប្រទេសអ្នកមានត្រូវជួយប្រទេសដែលក្រីក្រដើម្បីសម្រេចបាននូវចំណុចនេះ។

## ៥.៣ គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោក: ជនជាតិដើមភាគតិច (*OP៤.១០*)

២៧. គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោក ៤.១០ (ជនជាតិដើមភាគតិច) តម្រូវឱ្យមានវិធានការរៀបចំផែនការពិសេសដើម្បីការពារផលប្រយោជន៍របស់ជនជាតិដើមភាគតិចដែលមានអត្តសញ្ញាណសង្គម និងវប្បធម៌ ខុសគ្នាពីសង្គមភាពច្រើនដែលអាចធ្វើឱ្យពួកគេងាយរងគ្រោះក្នុងដំណើរការអភិវឌ្ឍ។

២៨. គោលនយោបាយនេះកំណត់ថាជនជាតិដើមភាគតិចអាចត្រូវបានគេកំណត់អត្តសញ្ញាណនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ដោយមានលក្ខណៈប្រែប្រួលក្នុងកំរិតខុសៗគ្នាដូចខាងក្រោម:

ក) កំណត់អត្តសញ្ញាណខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចណាមួយនិងមានការទទួលស្គាល់អត្តសញ្ញាណនេះពីអ្នកដទៃ។

ខ) មានការផ្សារភ្ជាប់ជាសមូហភាពទៅនឹងជម្រកដែលមានលក្ខណៈដោយឡែកទៅតាម ភូមិសាស្ត្រ ឬដែនដីបុព្វកាលនៅក្នុងតំបន់អនុវត្តគម្រោង និងផ្សារភ្ជាប់ជាមួយធនធាន ធម្មជាតិនៅទីជម្រកនិងដែនដីទាំងនេះ។

គ) ស្ថាប័នវប្បធ៌ម សេដ្ឋកិច្ច សង្គម ឬនយោបាយ ដាច់ដោយឡែកពីសង្គម និងវប្បធម៌ ពីសង្គមភាគច្រើន និង

ឃ) ភាសាជនជាតិដើមភាគតិច ជារឿយៗ ខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់នោះ។

២៩. ជាបុរេលក្ខខណ្ឌសម្រាប់ការអនុម័តសំណើគម្រោង OP ៤.១០ តម្រូវឱ្យអ្នកខ្ចីធ្វើការពិគ្រោះយោបល់ដោយសេរី និងមានការជូនដំណឹងជាមុនជាមួយនឹងប្រជាជនជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ និងដើម្បីបង្កើតគំរូនៃការគាំទ្រសហគមន៍ទូលំទូលាយសម្រាប់គម្រោង និងគោលបំណងរបស់គម្រោង។ សំខាន់ត្រូវកត់សម្គាល់ថា OP ៤.១០ សំដៅលើក្រុមសង្គម និងសហគមន៍ ពុំមែនសំដៅបុគ្គលឡើយ។ គោលបំណងចម្បងរបស់ OP ៤.១០ គឺ:

- ដើម្បីធានាថាក្រុមទាំងនោះមានឱកាសដ៏ប្រសើរក្នុងការចូលរួមរៀបចំផែនការសកម្មភាពគម្រោងដែលប៉ះពាល់ដល់ពួកគេ។
- ដើម្បីធានាឱ្យមានការពិចារណាដើម្បីឱ្យក្រុមនេះបានទទួលអត្ថប្រយោជន៍ផ្នែកវប្បធម៌បានសមរម្យ។ និង
- ដើម្បីធានាឱ្យមានការបញ្ចៀសផលប៉ះពាល់អវិជ្ជមានណាមួយរបស់គម្រោងចំពោះពួកគេឬត្រូវបានកាត់បន្ថយឱ្យនៅមានតិចបំផុត និងកាត់បន្ថយឥទ្ធិពល។

## ៥.៤ ការវិភាគអំពីគម្លាត

៣០. ថ្វីបើប្រទេសកម្ពុជាមានគោលនយោបាយមួយដែលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចចំពោះវប្បធម៌ ការអប់រំ ការអប់រំវិជ្ជាជីវៈ សុខភាព បរិស្ថាន ដីធ្លី កសិកម្មធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពលក្តី ក៏ពុំមានក្រឹត្យ អនុក្រឹត្យ ឬនីតិវិធីសម្រាប់ការពារជាក់លាក់ ឬគាំពារផលប្រយោជន៍របស់ជនជាតិដើមភាគតិច ក្រៅពីផលប្រយោជន៍ដីធ្លី និងព្រៃឈើនោះដែរ។ ច្បាប់ភូមិបាលនៃប្រទេសកម្ពុជាទទួលស្គាល់សិទ្ធិរបស់ សហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជាក្នុងការធ្វើជាម្ចាស់លើអចលនវត្ថុ ពោលគឺដីរបស់ពួកគេ ជាមួយនឹងកម្មសិទ្ធិសមូហភាព។ ជាក់ស្តែងនីតិវិធីដើម្បីចុះបញ្ជីកម្មសិទ្ធិសមូហភាពចំណាយពេលវេលាយូរណាស់ ហើយមានសហគមន៍ជនជាតិដើមភាគតិចតិចតួចប៉ុណ្ណោះ (ប្រហែល ៥) បានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពចាប់តាំងពីច្បាប់ភូមិបាលត្រូវបានអនុម័តក្នុងឆ្នាំ ២០០១ មក។ ស្រដៀងគ្នានេះដែរ ច្បាប់ព្រៃឈើក៏ធានា និងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការបន្តការប្រើប្រាស់ និងចូលទៅកាន់តំបន់ព្រៃឈើដែលពួកគេប្រើប្រាស់ និងអនុវត្តតាមបែបប្រពៃណី។ ដូច្នេះ នៅពេលដែលមានការបំពេញបន្ថែមច្បាប់និងបទប្បញ្ញត្តិមួយចំនួនរបស់ កម្ពុជាទាក់ទងនឹងជនជាតិដើមភាគតិច និង OP៤.១០ របស់ធនាគារពិភពលោក គេពុំឃើញមានបទ

ប្បញ្ញត្តិ ឬនីតិវិធីលម្អិតគ្រប់គ្រាន់ដើម្បីជួយសម្រួលដល់ការអនុវត្តឱ្យបានពេញលេញឡើយ។ ហេតុដូច្នេះ IPPF នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន OP៤.១០ របស់ធនាគារពិភពលោកដោយពិចារណាលើគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់កម្ពុជា។ IPPF បានដាក់ចេញនូវយន្តការច្បាស់លាស់សម្រាប់ការពិគ្រោះយោបល់ដោយសេរី និងមានការជូនដំណឹងជាមុនដើម្បីបង្កើតឱ្យមានការគាំទ្រគម្រោងនេះបានទូលំទូលាយពីសំណាក់សហគមន៍ ជនជាតិដើមភាគតិច ជាមួយនឹងនីតិវិធីនានាសម្រាប់បង្កើតការវាយតម្លៃសង្គម និងការរៀបចំផែនការជនជាតិដើមភាគតិច។ ក្នុងអំឡុងពេលអនុវត្ត យន្តការដោះស្រាយវិវាទនឹងត្រូវបានបង្កើតឡើងដើម្បីឱ្យជនជាតិដើមភាគតិចទាំងអស់អាចសម្តែងមតិ ដាក់បណ្តឹងតវ៉ា ឬលើកឡើងនូវការមិនពេញចិត្តណាមួយចំពោះគម្រោង។

# ៦. ការពិនិត្យ និងការវាយតម្លៃសង្គមបឋម

## ៦.១ ការពិនិត្យ

៣១. ការចុះពិនិត្យដល់មូលដ្ឋាន និងការសិក្សាស្រាវជ្រាវឯកសារបានរកឃើញថាជនជាតិដើមភាគតិចមានវត្តមានភាគច្រើនក្នុងខេត្តរតនៈគិរី មណ្ឌលគីរី ស្ទឹងត្រែង និងក្រចេះ (ភាគឦសានកម្ពុជា) ។ ក្រុមជនជាតិភាគតិចផ្សេងទៀតកំពុងរស់នៅក្នុងខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ (សួយ) ខេត្ត ព្រះសីហនុ (ស្អូច) កំពង់ចាម (ស្មៀង) កំពង់ធំ (គួយ) បន្ទាយមានជ័យ (គួយ) និងឧត្តរមានជ័យ (ចម្រុះ)។ សហគមន៍ជនជាតិដើមភាគតិចភាគច្រើនស្ថិតរស់នៅក្រៅក្រុងបានលុងនៃខេត្តមណ្ឌលគិរីដែលគ្មានបណ្តាញទឹក។ ហេតុនេះ សហគមន៍មូលដ្ឋានកំពុងប្រឈមនឹងការលំបាកក្នុងការជងទឹក ពិសេសនៅរដូវប្រាំង។ ខណៈពេលដែលបុរសភាគច្រើនរវល់ជាមួយការងារប្រចាំថ្ងៃរបស់ពួកគេ ស្ត្រី និងកុមារត្រូវសែង ឬរែកទឹកឆ្ងាយពីផ្ទះ។

## ៦.២ លទ្ធផលនៃការវាយតម្លៃសង្គមបឋម

៣២. នៅក្នុងខែមិថុនាឆ្នាំ ២០១៨ ក្រុមការងារមួយ រួមមាន មន្ត្រីទទួលបន្ទុក មកពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ត្រីបណ្តាញទឹកថ្នាក់ខេត្តបានធ្វើការវាយតម្លៃជាបន្តបន្ទាប់នៅក្រុងសែនមនោរម្យខេត្តមណ្ឌលគីរី ជាផ្នែកមួយនៃការវាយតម្លៃសង្គម (SA) ។ វិធីសាស្ត្រពិគ្រោះយោបល់ដោយមានការចូលរួមត្រូវបានប្រើប្រាស់ក្នុងទម្រង់នៃបច្ចេកទេសវាយតម្លៃរហ័សដែលមានការចូលរួម (PRA) ។ ការវាយតម្លៃបឋមដែលមានការចូលរួមនេះសំដៅកំណត់តម្រូវការទឹកស្អាតដោយប្រជាពលរដ្ឋមូលដ្ឋាន រួមមាន សហគមន៍ជនជាតិដើមភាគតិច បញ្ហាសំខាន់ៗដែលសហគមន៍របស់ពួកគេបានជួបប្រទះ និង គាំទ្រដល់ដំណើរការពិនិត្យមើលជនជាតិដើមភាគតិចតាមរយៈការផ្តល់ទិន្នន័យបន្ថែម ដើម្បីកំណត់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់អនុវត្តគម្រោង ហើយក៏បញ្ជាក់ផងដែរថាការតម្លើងបំពង់ថ្មី និងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកនៅក្នុងសហគមន៍របស់ពួកគេទទួលបានការគាំទ្រយ៉ាងទូលំទូលាយ និងរឹងមាំពីសហគមន៍មូលដ្ឋាន ហើយផ្តល់អត្ថប្រយោជន៍ដល់ពកគេ។ អ្នកចូលរួមក្នុងការពិគ្រោះយោបល់ទាំងនេះបានសំដែងការគាំទ្របឋមរបស់ខ្លួន ចំពោះគម្រោងនេះ។ លទ្ធផលនៃការវាយតម្លៃនោះត្រូវបានប្រើប្រាស់ដើម្បីរៀបចំឯកសារគាំពារ (រួមមាន IPPF និង ESMF នេះ)របស់គម្រោង ។

## ៦.៣ ផលប៉ះពាល់ដែលអាចកើតមានចំពោះជនជាតិដើមភាគតិច

៣៣. ទស្សនៈដូចខាងក្រោមនេះត្រូវបានភាគីពាក់ព័ន្ធក្នុងវិស័យផ្សេងៗ ដែលបានចុះមកមើលលើកឡើងថាជាផលប៉ះពាល់ដែលអាចមានលក្ខណៈវិជ្ជមាន៖

- ✓ ទឹកនឹងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
- ✓ ចំនួនអ្នកដែលមានទឹកស្អាតប្រើប្រាស់បានកើនឡើង
- ✓ ការកាត់បន្ថយជំងឺឆ្លងតាមទឹក
- ✓ លើកម្ពស់ស្ថានភាពអាហារូបត្ថម្ភ
- ✓ លើកកម្ពស់សន្តិសុខស្បៀង
- ✓ កម្រិតនៃភាពងាយរងគ្រោះត្រូវបានកាត់បន្ថយ
- ✓ ការកាត់បន្ថយកម្រិតនៃភាពក្រីក្រ
- ✓ លើកកម្ពស់កម្រិតនៃភាពស្អាត អនាម័យបរិស្ថាន និងអនាម័យខ្លួនប្រាណ
- ✓ ការកាត់បន្ថយការងារនិងចម្ងាយផ្លូវរបស់ស្ត្រីក្នុងការទៅដងទឹកពីស្ទឹង
- ✓ ពេលវេលាដែលត្រូវបានរំដោះពីការទៅដងទឹកចំពោះស្ត្រីត្រូវបានប្រើប្រាស់សម្រាប់គំនិត ផ្តួចផ្តើមអភិវឌ្ឍផ្សេងទៀត

៣៤. ប្រជាជនក្នុងស្រុករួមទាំងជនជាតិដើមភាគតិចដែលបានជួប បានលើកឡើងនូវផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងពីគម្រោង ដែលអាចរួមមានដូចជាៈ

- ✓ ការបង់ថ្លៃទឹក (ដែលបច្ចុប្បន្ននេះស្ត្រីដងយកដោយឥតគិតថ្លៃ)
- ✓ ត្រូវតែមានការយកចិត្តទុកដាក់ថែទាំប្រភពទឹក

៣៥. នៅក្នុងបរិបទនេះ IPPF ដាកចេញនូវដំណើរការ និងនីតិវិធីដែលត្រូវអនុវត្តនៅពេលពិនិត្យ និង អនុវត្តគម្រោង ដើម្បីធានាថាប្រជាជនជនជាតិដើមភាគតិចត្រូវបានពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ជាមួយសកម្មភាពគម្រោង មានការផ្តល់ឱកាសដើម្បីលើកឡើងនូវក្តីកង្វល់ និងចូលរួម ព្រមទាំងទទួលបានអត្ថប្រយោជន៍ពីគម្រោង។ ផ្នែកខាងក្រោមរៀបរាប់អំពីសកម្មភាពដែលនឹងត្រូវធ្វើក្នុងអំឡុងពេលរៀបចំកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យតាមទីប្រជុំជនតូច និងកម្មវិធីដែលត្រូវធ្វើក្នុងអំឡុងពេលអនុវត្ត។

# ៧. យន្តការអនុវត្តការរៀបចំ ការតាមដាន និងបណ្តឹងសារទុក្ខ

## ៧.១ ការរៀបចំការអនុវត្ត

៣៦. ការអនុវត្ត IPPF នឹងអនុវត្តតាមការរៀបចំអនុវត្តរបស់គម្រោង។ MIH និង MPWT នឹងបង្កើតផ្នែកគ្រប់គ្រងសមាសភាគទី ១ (CMU-១) សម្រាប់សមាសភាគទី ១ និងផ្នែកគ្រប់គ្រងសមាសភាគទី ២ (CMU-២) សម្រាប់សមាសភាគទី ២ ។ CMU-១ និង CMU-២ នឹងអនុវត្តនូវការទទួលខុសត្រូវចំពោះសមាសភាគនីមួយៗរបស់ខ្លួនលើការងារប្រចាំថ្ងៃ និងការទទួលខុសត្រូវលើការងារ ដូចជា ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម តាមដានវឌ្ឍនភាពរបស់គម្រោង និងធ្វើការតាមដាននិងវាយតម្លៃ ជានានូវការគោរពចំពោះការគាំពារសង្គម និងបរិស្ថានគម្រោង រៀបចំរបាយការណ៍គម្រោង ត្រួតពិនិត្យកិច្ចការសំណង់ស៊ីវិល សម្របសម្រួល និងប្រមូលជាតុចូលពីក្រសួងពាក់ព័ន្ធទាក់ទងនឹងសមាសជាតុគម្រោងរបស់ខ្លួន។

### អង្គភាពគ្រប់គ្រងសមាសភាគទី ១

៣៧. CMU-១ ដឹកនាំដោយនាយកមួយរូប (CD-១) ដែលតែងតាំងដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់សមាសភាគទី ១ នៃគម្រោង នាយករូបនេះ នឹងទទួលខុសត្រូវរាល់ការងារគ្រប់គ្រងទូទៅ និងគ្រប់គ្រងផ្នែករដ្ឋបាល ក្នុងសមាសភាគទី ១នេះ ជានាថាសម្រេចបានគោលដៅនៃការអភិវឌ្ឍគម្រោង។ នាយផ្នែកមួយរូបសម្រាប់សមាសភាគទី១ នៃគម្រោង តែងតាំងដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មកពី អគ្គនាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាត ទទួលបន្ទុកគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ និងរដ្ឋបាលរបស់គម្រោង។ ជានាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍គម្រោង រួមមានការអនុម័ត និងការចុះហត្ថលេខាលើកិច្ចសន្យា និងឯកសារសំខាន់ៗដទៃទៀតរបស់គម្រោង ធ្វើលទ្ធកម្មពាក់ព័ន្ធនឹងសមាសភាគទី ១ អនុម័តការចំណាយរបស់ផ្នែករបស់គម្រោង ជានាការអនុវត្តទាន់ពេលវេលា និងប្រតិបត្តិតាម POM ជានាការអនុវត្តតាមតម្រូវការការពារផលប៉ះពាល់ រាយការណ៍តាមខ្សែបណ្តោយក្នុងក្រសួងស្តីពីវឌ្ឍនភាពគម្រោង និងការរៀបចំរបាយការណ៍នានាពាក់ព័ន្ធនឹងគម្រោងទាន់ពេលវេលា។

៣៨. នាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងផ្តល់នូវជំនួយបច្ចេកទេសដល់ CMU-១ តាមដានដំណើរការវឌ្ឍនភាពគម្រោង និងគាំទ្រដល់ការគ្រប់គ្រងគម្រោង CMU-១។ នាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យ នឹងគាំទ្រដល់ការតាមដាននិងវាយតម្លៃរបស់គម្រោងដោយជានាថាទិន្នន័យ និងព័ត៌មានត្រូវបានប្រមូលទាន់ពេលវេលាសម្រាប់របាយការណ៍នៅក្នុង CMU-១។ នាយកដ្ឋានទឹកស្អាតនឹងផ្តល់កិច្ចគាំទ្រពិនិត្យមើលការចូលរួមរបស់វិស័យឯកជននៅក្នុងគម្រោង ជានាឱ្យបាននូវការប្រតិបត្តិតាមគោលនយោបាយ និងបទបញ្ជារបស់រាជរដ្ឋាភិបាល រៀបចំកិច្ចសន្យា និងការគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ ឬបទប្បញ្ញត្តិចាំបាច់ណាមួយ ដើម្បីឱ្យមានការចូលរួមយ៉ាងសកម្មពីវិស័យឯកជន។

៣៩. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងគាំទ្រ CMU-១ នៅក្នុងគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងសមាសភាគទី១។ អង្គភាពលទ្ធកម្ម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងគាំទ្រ CMU-១ នូវរាល់ទិដ្ឋភាពលទ្ធកម្មនៃសមាសភាគទី១នេះ។ ដោយសារតែក្រសួងឧស្សាហកម្ម និងសិប្បកម្ម មិនមានផ្នែកបរិស្ថាន និងសង្គម នៅក្នុងក្រសួង ដូច្នេះក្រសួងឧស្សាហកម្ម និងសិប្បកម្ម តែងតាំងជនបង្គោលមួយរូបពី DTPM ដើម្បីគាំទ្រ CMU-១ ដើម្បីពិនិត្យមើលតម្រូវការកិច្ចការការពារផលប៉ះពាល់បរិស្ថាន និងសង្គម។

៤០. CMU-១ ទទួលបានការគាំទ្រពីក្រុមគាំទ្រគម្រោងទី ១ (PST-១) នៅថ្នាក់ខេត្ត។ ក្រុមការងារនេះនឹងទទួលបានការចាត់តាំងពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មកពី មន្ទីរឧស្សាហកម្ម និងសិប្បកម្ម តាមខេត្ត និងរដ្ឋាករទឹកដែលពាក់ព័ន្ធផ្ទាល់នឹងគម្រោង។ PST-១ នឹងផ្តល់ការគាំទ្រដល់ CMU-១ ក្នុងការត្រួតពិនិត្យកិច្ចការសាងសង់ទៅដល់ទីតាំង ឃ្លាំមើលសកម្មភាពវឌ្ឍនភាព សម្របសម្រួលនៅថ្នាក់ខេត្ត ទាក់ទងកិច្ចពិភាក្សាយោបល់អំពីគម្រោង និងរាយការណ៍ទៅនាយផ្នែកគ្រប់គ្រង CMU-១។

**អង្គភាពគ្រប់គ្រងសមាសភាគទី ២**

៤១. CMU-២ ដឹកនាំដោយនាយកមួយរូប )CD-២) ដែលតែងតាំងដោយ ក្រសួងសាធារណការ និងដឹកជញ្ជូនពីអគ្គនាយកដ្ឋានសាធារណការ )GDPW) សម្រាប់សមាសភាគទី ២ នៃគម្រោង នាយករូបនេះនឹងទទួលខុសត្រូវរាល់ការងារគ្រប់គ្រងទូទៅ និងគ្រប់គ្រងផ្នែករដ្ឋបាល ក្នុងសមាសភាគទី ២នេះ ធានាថាសម្រេចបានគោលដៅនៃការអភិវឌ្ឍគម្រោង។ )CD-២) អនុម័ត និងចុះហត្ថលេខាលើកិច្ចសន្យា និងឯកសារសំខាន់ៗទាំងឡាយរបស់គម្រោង ធានាឱ្យទាន់ពេលវេលានូវសកម្មភាពលទ្ធកម្ម អនុម័តលើការចំណាយលើផ្នែកគម្រោង ធានាការអនុវត្តទាន់ពេលវេលា និងប្រតិបត្តិតាម POM ធានាការប្រើប្រាស់សម្បត្តិរបស់គម្រោងបានត្រឹមត្រូវ ដោយប្រាកដថាក្រុមការងារនៅក្នុងគម្រោងទទួលបានមធ្យោបាយសម្រាប់បំពេញភារកិច្ចរៀងៗខ្លួន រាយការណ៍តាមខ្សែបណ្តោយក្នុងក្រសួង ស្តីពីវឌ្ឍនភាពគម្រោង។ នាយផ្នែកគ្រប់គ្រងសមាសភាគ (CM-២) តែងតាំងដោយ ក្រសួងសាធារណការ និងដឹកជញ្ជូនពី GDPW នឹងទទួលខុសត្រូវចំពោះសកម្មភាពប្រចាំថ្ងៃនៃការអនុវត្តគម្រោង ដើម្បីធានាថាគម្រោងកំពុងវិវឌ្ឍន៍តាមកាលវិភាគរបស់សមាសភាគទី ២ ។CM-២ នឹងអនុវត្តសកម្មភាពលទ្ធកម្ម ធានាប្រតិបត្តិតាមតម្រូវការការពារផលប៉ះពាល់ និងរៀបចំរបាយការណ៍នានាពាក់ព័ន្ធនឹងគម្រោងទាន់ពេលវេលា។

៤២. នាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ (SMCD) នៃក្រសួងសាធារណការ និងដឹកជញ្ជូន នឹងទទួល

ខុសត្រូវចូលរួមផ្នែកបច្ចេកទេស និងគុណភាពនៃសមាសភាគទី២ តាមដានវឌ្ឍនភាពគម្រោង គាំទ្រការគ្រប់គ្រងគម្រោងរបស់ CMU-២ និងការប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ និងការធ្វើរបាយការណ៍ CMU-២។ នាយកដ្ឋានហិរញ្ញវត្ថុ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងគាំទ្រ CMU-២ នៅក្នុងគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោង។ អង្គភាពលទ្ធកម្ម របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងគាំទ្រ CMU-២ នៅក្នុងគ្រប់ផ្នែកនៃលទ្ធកម្មនៃសមាសភាគ២។ ការិយាល័យបរិស្ថាន និងសង្គម នៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងគាំទ្រ CMU-២ ក្នុងការត្រួតពិនិត្យលើតម្រូវការការពារផលប៉ះពាល់បរិស្ថាន និងសង្គម។

៤៣. CMU-២ ទទួលបានការគាំទ្រពីក្រុមគាំទ្រគម្រោងទី ២ (PST-២) នៅថ្នាក់ខេត្ត។ ក្រុមការងារនេះនឹងទទួលបានការចាត់តាំងពីក្រសួងសាធារណការ និងដឹកជញ្ជូន មកពី មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងអង្គភាពលូទឹកនិងស្ថានីយចម្រោះទឹកកខ្វក់នៅសៀមរាប។ PST-២ នឹងផ្តល់ការគាំទ្រដល់ CMU-២ ក្នុងការត្រួតពិនិត្យកិច្ចការសាងសង់ទៅដល់ទីតាំង ឃ្លាំមើលសកម្មភាពវឌ្ឍនភាព សម្របសម្រួលនៅថ្នាក់ខេត្ត ទាក់ទងកិច្ចពិភាក្សាយោបល់អំពីគម្រោង និងរាយការណ៍ទៅនាយផ្នែកគ្រប់គ្រង CMU-២។

## អង្គភាពសម្របសម្រួលគម្រោង

៤៤. អង្គភាពសម្របសម្រួលគម្រោង )PCU) នឹងត្រូវបង្កើតឡើងដើម្បីសម្របសម្រួល CMU-១ និង CMU-២ ។ PCU មិនមានការទទួលខុសត្រូវគ្រប់គ្រង CMU-១ និង CMU-២ ទេ ព្រោះ CMU នីមួយៗមានទំនួលខុសត្រូវគ្រប់ទិដ្ឋភាព មានការទុកចិត្ត និងតម្រូវការការពារផលប៉ះពាល់។ ទោះជាយ៉ាងណាក៏ដោយ PCU ទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តគម្រោង ធ្វើរបាយការណ៍រួមស្តីពីវឌ្ឍនភាពរបស់គម្រោង និងធ្វើសវនកម្មលើគម្រោងទាំងមូល។ ប្រធាន PCU នឹងត្រូវបានតែងតាំងដោយ ក្រសួងសាធារណការ និងដឹកជញ្ជូនជាអ្នកសម្របសម្រួលគម្រោង ហើយសមាជិក PCU គឺជានាយកផ្នែកសមាសភាគ និងនាយផ្នែក CMU-១ និង CMU-២។ គម្រោងនេះនឹងរួមបញ្ចូលការគាំទ្រដល់ប្រតិបត្តិការរបស់ PCU។

## គណៈកម្មាធិការដឹកនាំ

៤៥. គណៈកម្មាធិការដឹកនាំមួយ) SC) នឹងត្រូវបង្កើតឡើង ដើម្បីផ្តល់ការណែនាំនិងការសម្របសម្រួលជារួម។ គណៈកម្មាធិការដឹកនាំ រួមមានតំណាងជាន់ខ្ពស់មកពី MPWT, MIH, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ )MEF) ក្រសួងសុខាភិបាល គណៈកម្មាធិការជាតិសម្រាប់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ )NCDD-S) និង MRD ។ គណៈកម្មាធិការដឹកនាំៗដោយ MPWT ។ គណៈកម្មាធិការ

ដឹកនាំនឹងរៀបចំកិច្ចប្រជុំប្រចាំឆមាស ជួយសម្របសម្រួលអន្តរក្រសួង ត្រួតពិនិត្យវឌ្ឍនភាពរបស់គម្រោងជារួម ដឹកនាំកិច្ចពិភាក្សាគោលនយោបាយ និងផ្តល់ការណែនាំជាយុទ្ធសាស្ត្រ។ ក្រសួងសុខាភិបាលនឹងចូលរួមជាមួយគណៈកម្មាធិការដឹកនាំ ដើម្បីផ្តល់ការណែនាំលើទិដ្ឋភាពអាហារូបត្ថម្ភរបស់គម្រោង។ NCDD-S នឹងផ្តល់ធាតុចូល និងការណែនាំអំពីការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងគម្រោងនានា។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងណែនាំការអនុវត្តយុទ្ធនាការប្រាស្រ័យទាក់ទងសង្គម ដើម្បីអនាម័យបរិស្ថាន និងអនាម័យខ្លួនប្រាណ ខណៈពេលដែលក្រសួងអភិវឌ្ឍន៍ជនបទគឺជាអ្នកកសាងកញ្ចប់ប្រាស្រ័យទាក់ទងចម្បង។

៤៦. **មន្ទីរឧស្សាហកម្មនិងសិប្បកម្មថ្នាក់ខេត្ត និងរដ្ឋាករទឹក** គឺជាការិយាល័យថ្នាក់ក្រោមជាតិរបស់ MIH ដែលជាទំនាក់ទំនងរវាង MIH និងសហគមន៍ / អាជ្ញាធរមូលដ្ឋាន។

៤៧. **ទីប្រឹក្សាខាងគាំពារសង្គម**នឹងត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការគាំពារមន្ត្រីទំនាក់ទំនងសំដៅធានាឱ្យការវាយតម្លៃសង្គមត្រូវបានបំពេញ រួមជាមួយដំណើរការពិគ្រោះយោបល់ដោយសេរី និងដែលមានការផ្តល់ដំណឹងជាមុន ហើយដែលផែនការជនជាតិដើមភាគតិចត្រូវបានរៀបចំ និង អនុវត្តន៍។

## ៧.២ ការតាមដាន ការចងក្រងឯកសារ ការធ្វើរបាយការណ៍សម្រាប់ WaSSIP

៤៨. ជាមួយនឹងវិសាលភាពដែលមានទំហំតូចនៃការងារសំណង់ស៊ីវិល ត្រូវបានអនុវត្ត នៅក្នុងតំបន់គោលដៅដែលស្ថិតនៅក្រោម WaSSIP ហើយការជ្រើសរើសការវិនិយោគអាទិភាពនឹងធ្វើតាមដំណើរការរៀបចំផែនការ និងពិគ្រោះយោបល់ដែលមានការចូលរួម ដូចបានពិពណ៌នានៅក្នុងគោលនយោបាយនេះ ផលប៉ះពាល់អវិជ្ជមានជាច្រើនមកលើដីរបស់ជនជាតិដើមភាគតិច និងធនធានមិនត្រូវបានរំពឹងថានឹងកើតឡើងនោះទេ។ ដូច្នេះ WaSSIP នឹងខិតខំពង្រឹងសមត្ថភាពតាមដាន និងបញ្ហាដោះស្រាយបញ្ហាសហគមន៍មូលដ្ឋានដោយខ្លួនឯង ប៉ុន្តែមិនកំណត់តែចំពោះសហគមន៍ជនជាតិដើមភាគតិចនោះទេ។ ការតាមដាន និងវាយតម្លៃដែលមានការចូលរួមនឹងត្រូវអនុវត្តន៍ក្នុងកំឡុងពេលអនុវត្តន៍ ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់វាយតម្លៃផលប៉ះពាល់គម្រោង និងកំណត់វិធានការដើម្បីពង្រីកអត្ថប្រយោជន៍វិជ្ជមាន និងដោះស្រាយផលប៉ះពាល់អវិជ្ជមាន។ ម្យ៉ាងទៀតពិនិត្យមើលថាតើជម្លោះទាក់ទងនឹងក្រុមជនជាតិភាគតិចបានកើតឡើង និងត្រូវបានដោះស្រាយដោយអនុលោមតាមឯកសារនេះដែរឬយ៉ាងណា និងរាយការណ៍ដោយមន្ត្រីសម្រប សម្រួល។ ការណ៍នេះនឹងមានកិច្ចប្រជុំទៀងទាត់ (ប្រចាំខែ / ត្រីមាស) រវាងភូមិ មន្ទីរតបណ្តាញទឹក និងអ្នកម៉ៅការ ដែលត្រូវសម្របសម្រួលដោយមន្ត្រីទំនាក់ទំនងផ្នែកការពារសង្គម / កុងស៊ុលតង់ពិគ្រោះយោបល់ផ្នែកការពារសង្គម។ កិច្ចប្រជុំទាំងនេះនឹងត្រូវបានចងក្រងជាឯកសារ ហើយមតិត្រឡប់នឹងត្រូវបានចែករំលែកជាមួយ CMU រៀងៗខ្លួន ។

៤៩. CMU តាមរយៈមន្ត្រីសម្របសម្រួលរបស់ខ្លួននឹងធ្វើការតាមដាននិងវាយតម្លៃផ្ទៃក្នុងជាទៀងទាត់លើ IPPF / IPP រួមទាំងការពិនិត្យឡើងវិញនូវរបាយការណ៍វឌ្ឍនភាពប្រចាំខែដែលបានដាក់ជូនដោយវិស្វករការដ្ឋាន។ ការតាមដាន និងវាយតម្លៃនេះមានបំណងជួយធានាថា IPPF / IPP ត្រូវបានរៀបចំស្របតាម OP៤.១០ និងស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងឱ្យអនុវត្តតាមការគ្រោងទុក។ ការតាមដានផ្ទៃក្នុងនឹងត្រូវធ្វើឡើងរៀងរាល់ពីរខែម្តងដោយ មន្ត្រីសម្របសម្រួលផ្នែកការពារសង្គម។ រាល់របកគំហើញនៃការតាមដានផ្ទៃក្នុងគប្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់គម្រោងដែលផ្ញើទៅធនាគារពិភពលោករៀងរាល់ ៦ ខែម្តង។ នៅក្នុងឯកសារ IPP សូចនាករតាមដានត្រូវតែបញ្ជាក់ឱ្យបានច្បាស់ ។

៥០. **អ្នកជំនាញផ្នែកការពារសង្គមរបស់ធនាគារពិភពលោក** នឹងផ្តល់ការគាំទ្រដល់ការតាមដាន និងការអនុវត្ត IPPF / IPP និងការអនុលោម។ អ្នកជំនាញផ្នែកសង្គមអាច (ក) ធ្វើទស្សនកិច្ចជាប្រចាំនៅតាមទីតាំងគម្រោង (យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ) ដើម្បីពិនិត្យមើលវឌ្ឍនភាព IPPF / IPP និងបញ្ហាអនុលោមភាព។ (ខ) ពិនិត្យមើលថាថាតើមន្ត្រីសម្របសម្រួលរបស់ CMU បានធ្វើ ឬមិនបានធ្វើការពិគ្រោះយោបល់ដោយសេរី និងមានការជូនដំណឹងជាមុនជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដែរ ឬយ៉ាងណា។ (គ) ការសម្របសម្រួលសកម្មភាព IPPF / IPP ជាមួយនឹងកាលវិភាគសាងសង់។ (ឃ) វាស់វែងកម្រិតនៃការពេញចិត្តរបស់ IPP ជាមួយនឹងបទប្បញ្ញត្តិនិងការអនុវត្តសកម្មភាពរបស់ IPPF / IPP ។ (ង) ពិនិត្យមើលយន្តការនិងនីតិវិធីនៃការដោះស្រាយបណ្តឹងសារទុក្ខ។ និង (ច) ធ្វើការបណ្តុះបណ្តាលអំពីការពារសង្គមដល់ MIH និង MPWT។

## ៧.៣ តម្លាភាព និងយន្តការបណ្តឹងសារទុក្ខ

៥១. គោលនយោបាយការតាំងទីលំនៅថ្មីរបស់ធនាគារពិភពលោកតម្រូវឱ្យមានគម្រោងវិនិយោគ ដើម្បីបង្កើតយន្តការសម្រាប់ដោះស្រាយបណ្តឹងសារទុក្ខ ដើម្បីធានាដល់ការពេញចិត្តរបស់ជនជាតិដើមភាគតិចចំពោះការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹង IPPF និងផ្តល់ឱ្យភាគីជនជាតិដើមភាគតិចនូវវេទិកាស្របច្បាប់ សម្រាប់ការតាមដានជាក់ស្តែង និងរាយការណ៍អំពីការអនុវត្ត សកម្មភាពពាក់ព័ន្ធរបស់ IPPF ។ ពិសេស គោលបំណងនៃយន្តការបណ្តឹងសារទុក្ខនេះគឺអនុញ្ញាតឱ្យជនជាតិដើមភាគតិច និងអ្នកដែលជឿថាពួកគេរងផលប៉ះពាល់ ស្វែងរកដំណោះស្រាយចំពោះសារទុក្ខដែលអាចមានរបស់ពួកគេទាក់ទងនឹងលទ្ធភាពទទួលបានដី ការដាក់កំហិតលើធនធាន ឬអន្តរាគមន៍ផ្សេងទៀតរបស់គម្រោង។ គោលការណ៍គន្លឹះនៃយន្តការ បណ្តឹងសារទុក្ខនេះគឺដើម្បីធានាថា៖

(ក) សិទ្ធិជាមូលដ្ឋាននិងផលប្រយោជន៍នានារបស់ជនជាតិដើមភាគតិចត្រូវបានការពារ

(ខ) ការព្រួយបារម្ភរបស់ជនជាតិដើមភាគតិចដែលកើតឡើងពីដំណើរការនៃការអនុវត្តគម្រោងត្រូវបានដោះស្រាយឱ្យបានគ្រប់គ្រាន់។ និង

(គ) សិទ្ធិទទួលបានឬការគាំទ្រដល់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចត្រូវបានផ្តល់ទាន់ពេលវេលា និងស្របតាមគោលនយោបាយស្តីពីការការពាររបស់រដ្ឋាភិបាល និងគោលនយោបាយស្តីពីការការពាររបស់ធនាគារពិភពលោកដែលបានបញ្ជាក់ពីខាងលើ។

(ឃ) ជនជាតិដើមភាគតិចយល់ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបាន និងត្រូវមានចំពោះនីតិវិធីបណ្តឹងសារទុក្ខ ដោយឥតបង់ប្រាក់សម្រាប់គោលបំណងខាងលើនេះ។

(ង) នីតិវិធីបណ្តឹងសារទុក្ខគឺជាផ្នែកមួយនៃគណៈកម្មាធិការផែនការរួមរបស់ឃុំ / សង្កាត់ មេឃុំ និងយន្តការក្រុមប្រឹក្សា ហើយបង្កើតបានជាផ្នែកមួយដ៏សំខាន់នៃយន្តការដោះស្រាយវិវាទដែលមានមូលដ្ឋាននៅតាមផ្អែកលើសហគមន៍ ពាក់ព័ន្ធនឹងតំណាងក្រុមជនងាយរងគ្រោះ ដែលត្រូវបានគ្រប់គ្រងរួមគ្នា។

៥២. នៅពេលចាប់ផ្តើមការអនុវត្តស្តង់ដារ WaSSIP គណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខនឹងត្រូវបានបង្កើតឡើងនៅតាមឃុំ ស្រុក និងថ្នាក់ខេត្ត ត្រូវបានកសាងឡើងលើរចនាសម្ព័ន្ធដែលមានស្រាប់ រួមមានមន្ទីរពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ តំណាងស្ត្រី និងតំណាងជនជាតិភាគតិច ប្រសិនបើមាន។ អ្នកបម្រើការនៅ មន្ទីរតបណ្តាញទឹកគឺជាសមាជិកគណៈកម្មាធិការមួយរូបនៅថ្នាក់ស្រុក រីឯមន្ត្រីទំនាក់ទំនងការងារការពារសង្គម ក៏ជាផ្នែកមួយនៃគណៈកម្មការដោះស្រាយវិវាទនៅថ្នាក់ជាតិផងដែរ។ នៅតាមភូមិយន្តការបណ្តឹងដែលមានស្រាប់ត្រូវបានដឹកនាំដោយអ្នកដឹកនាំវ័យចាស់ និង/ឬដឹកនាំដោយមេកន្ទ្រាញ/មេកុលសម្ព័ន្ធ ដែលសហគមន៍មូលដ្ឋានមួយផ្នែកធំអាចទទួលយកបាន និងត្រូវបានពង្រឹងជាយន្តការ ដោះស្រាយវិវាទលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ ការរៀបចំបែបនេះជួយធានាឱ្យប្រព័ន្ធមួយត្រូវបានបង្កើតឡើងដើម្បីជួយដោះស្រាយសារទុក្ខ ឬបណ្តឹងដែលអាចកើតឡើងបន្ទាប់ពីមានអន្តរាគមន៍របស់គម្រោង។ យន្តការបណ្តឹងសារទុក្ខនឹងត្រូវអនុវត្តចំពោះបុគ្គល ឬក្រុមដែលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ក៏ដូចជាអ្នកដែលមានចំណាប់អារម្មណ៍ចំពោះគម្រោង និង/ឬមានសមត្ថភាពជះឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានលើលទ្ធផលរបស់ខ្លួន ។ WaSSIP នឹងផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដើម្បីពង្រឹងរចនាសម្ព័ន្ធ ដែលមានស្រាប់ទាំងនេះ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាព និងដោះស្រាយរួមគ្នាចំពោះការព្រួយបារម្ភដែលអាចត្រូវបានលើកឡើងដោយ PAPs ក្នុងកំឡុងវគ្គ បណ្តុះបណ្តាលនិងបន្ទាប់ពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។

៥៣. ក្នុងការអនុវត្តធម្មតា ប្រសិនបើគម្រោងពាក់ព័ន្ធនឹងការអនុវត្តលទ្ធកម្មដីធ្លី គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខ (GRC) ត្រូវបានបង្កើតឡើងសម្រាប់ WaSSIP ។ GRC នឹងដោះស្រាយគ្រប់ទិដ្ឋភាពទាំងអស់នៃសំណើអនុគម្រោង រួមមាន បរិស្ថាន ការតាំងទីលំនៅឡើងវិញ និងបញ្ហាជនជាតិដើមភាគតិច (ប្រសិនបើមាន) តាមរយៈការចរចាក្នុងបំណងឈានដល់ការមូលមតិគ្នាជាឯកច្ឆន្ទ ។ MIH, MPWT ឬ IRC (ប្រសិនបើ IRC ពាក់ព័ន្ធក្នុងការអនុវត្ត ARAP / RAP) ស្នើសុំទៅអភិបាលខេត្តឱ្យបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់មូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយអភិបាលខេត្ត ឬអភិបាលរងខេត្ត ប្រធានស្រុក និងមេឃុំ។ សម្រាប់យន្តការដោះស្រាយបណ្តឹងសាទុក្ខ (GRM) នៅកម្រិតឃុំ សមាជិក GRM ក៏មានតំណាង AH / IP (អ្នកតំណាងរបស់ AH / IP ត្រូវបានជ្រើសរើសក្នុងចំណោម PAPs ឬក្នុងចំណោមសហគមន៍ IP) ។ គណៈ

កម្មាធិការទាំងនេះនឹងទទួល វាយតម្លៃ និងសម្របសម្រួលដំណោះស្រាយបញ្ហាកង្វល់ បណ្តឹង និងសារទុក្ខរបស់ PAP /IP និងPAH ។ គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនឹងដំណើរការ ដើម្បីផលប្រយោជន៍របស់ PAP / IP និង PAH ក្នុងកំឡុងពេលពេញមួយជីវិតរបស់ WaSSIP និងយូរជាងនេះ។

៥៤. PAPs ឬជនជាតិដើមភាគតិច ប្រសិនបើមិនពេញចិត្ត ឬមិនច្បាស់អំពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មី / IPPF រួមទាំងការផ្តល់សំណង ឬការកែលម្អជីវភាព អាចប្តឹងទៅក្រុមប្រឹក្សាឃុំ ដែលជាកម្រិតទាបបំផុតនៃ GRC នៅសហគមន៍ និងអាចបញ្ជូនទៅថ្នាក់ស្រុក និងខេត្តប្រសិនបើ PAP / IP មិនពេញចិត្តជាមួយដំណោះស្រាយ ឬការពន្យល់បំភ្លឺ។

៥៥. **នៅថ្នាក់ឃុំ:** PAP / IP ដែលរងផលប៉ះពាល់អាចដាក់ពាក្យបណ្តឹងរបស់គាត់ទៅកាន់មេឃុំ ដោយផ្ទាល់។ មេឃុំនឹងកោះប្រជុំក្រុមនោះដើម្បីសម្រេចចិត្តអំពីដំណើរការនៃការដោះស្រាយពាក្យបណ្តឹងក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីការដាក់ពាក្យបណ្តឹងរបស់ PAP/IP ។ កិច្ចប្រជុំរបស់ក្រុមនេះនឹងមានមេឃុំតំណាងមកពីសហគមន៍រួមទាំងមេដឹកនាំប្រពៃណី។ កិច្ចប្រជុំរបស់ក្រុមនេះមានមេឃុំ តំណាងនានាមកពីសហគមន៍ រួមទាំងមេដឹកនាំប្រពៃណី។ មេឃុំទទួលបន្ទុកចងក្រងឯកសារ និងរក្សាទុកឯកសារបណ្តឹងទាំងអស់ដែលបញ្ជូនឆ្លងកាត់រូបគាត់។ ប្រសិនបើរយៈពេល ១៥ ថ្ងៃដែល PAP / IP ដែលបានប្តឹងសារទុក្ខ មិនបានទទួលដំណឹងពីក្រុមប្រឹក្សាឃុំ ឬប្រសិនបើ PAP / IP មិនពេញចិត្តជាមួយការសម្រេចចិត្តនៅដំណាក់កាលដំបូងនេះ ពាក្យបណ្តឹងអាចត្រូវបានបញ្ជូនទៅការិយាល័យស្រុកជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

៥៦. **នៅថ្នាក់ស្រុក:** ការិយាល័យស្រុកមានរយៈពេល ១៥ ថ្ងៃក្នុងការដោះស្រាយពាក្យបណ្តឹង ដើម្បីបំពេញចិត្តអ្នកពាក់ព័ន្ធទាំងអស់។ ប្រសិនបើពាក្យបណ្តឹងមិនអាចដោះស្រាយបានក្នុងដំណាក់កាលនេះ ការិយាល័យស្រុកនឹងបញ្ជូនសំណុំរឿងទៅគណៈកម្មាធិការដោះស្រាយវិវាទសំរេចថ្នាក់ខេត្ត។

៥៧. **នៅថ្នាក់ខេត្ត:** គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខថ្នាក់ខេត្តដែលមានអភិបាលខេត្ត ឬអភិបាលខេត្តរងជាប្រធានគណៈកម្មាធិការ និងជាប្រធានមន្ទីរពាក់ព័ន្ធជាសមាជិកនឹងជួបជាមួយភាគីសារទុក្ខ ហើយព្យាយាមដោះស្រាយបណ្តឹង។ ក្នុងរយៈពេល ៣០ ថ្ងៃនៃការដាក់បណ្តឹងសារទុក្ខទៅកាន់គណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខថ្នាក់ខេត្តត្រូវធ្វើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរ និងជូនដំណឹងទៅកាន់ PAP / IP ជាលាយលក្ខណ៍អក្សរ។

៥៨. **តុលាការខេត្ត:** ប្រសិនបើភាគីបណ្តឹង PAP / IP មិនពេញចិត្តជាមួយនឹងដំណោះស្រាយរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខថ្នាក់ខេត្ត ផ្អែកលើគោលនយោបាយដែលបានព្រមព្រៀងគ្នាក្នុង RPF-RAP ឬ IPPF-IPP នោះ PAP / IP អាចបញ្ជូនករណីនេះទៅតុលាការខេត្ត។ ក្នុងអំឡុងពេលវិវាទរឿងក្តី រាជរដ្ឋាភិបាលកម្ពុជានឹងស្នើតុលាការឱ្យដំណើរការក្តីប្រព្រឹត្តទៅដោយគ្មានការរំខាននៅពេលធ្វើសវនាការ។ ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការខេត្ត នោះភាគីនោះអាចបញ្ជូនរឿងក្តីនោះទៅតុលាការជាន់ខ្ពស់បាន។ រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តសេចក្តីសំរេចរបស់តុលាការ។

៥៩. នៅក្នុងតំបន់គោលដៅដែលជនជាតិដើមភាគតិចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ពាក្យបណ្ដឹងទាំងអស់នឹងត្រូវពិភាក្សាជាមួយអ្នកភូមិដោយមានវត្តមានមេភូមិ ឬចាស់ទុំ និងការចរចារត្រូវបានអនុវត្តនៅក្នុងសហគមន៍ ឬក្នុងភូមិដែលមាន PAP និង PAH រស់នៅ។ ក្នុងករណីចាំបាច់ អ្នកគាំទ្រការសាងសង់នឹងផ្តល់ជំនួយដើម្បីឱ្យសិទ្ធិរបស់ជនជាតិដើមភាគតិចត្រូវបានការពារ។

## ៧.៣ ការកសាងសមត្ថភាព

៦០. ការវាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាល (TNA) នឹងប្រព្រឹត្តទៅដើម្បីរៀបចំឯកសារបណ្តុះបណ្តាលដែលពាក់ព័ន្ធចំពោះតម្រូវ។ TNA នឹងត្រូវប្រព្រឹត្តទៅក្នុងចំណោម CMU ទីប្រឹក្សាខាងគាំពារសង្គម និងសហគមន៍។ ការបណ្តុះបណ្តាលនឹងគ្របដណ្តប់លើគោលនយោបាយការពារចំនួនបី និងការអនុលោម ពោលគឺ បរិស្ថាន ការតាំងទីលំនៅដោយបង្ខំ និងជនជាតិដើមភាគតិច។ ជាមួយនឹងការបណ្តុះបណ្តាលជាក់លាក់របស់ IPPF / IPP ការបណ្តុះបណ្តាល រួមមាន (ក) ទិដ្ឋភាពទូទៅនៃ OP៤.១០ របស់ធនាគារពិភពលោក និងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់កម្ពុជា។ (ខ) មាតិកានៃ IPPF / IPP និងបញ្ហាអនុវត្ត (គ) ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តគម្រោងរួមមានតួនាទី និងការទទួលខុសត្រូវ។ (ឃ) របៀបធ្វើការពិគ្រោះយោបល់ជាសាធារណៈដោយប្រើវិធីសាស្ត្រពិគ្រោះយោបល់ដោយសេរី និងជូនដំណឹងជាមុន។ (ង) នីតិវិធី និងបញ្ហានៃការដោះស្រាយបណ្តឹង សារទុក្ខ និង (ច) កិច្ចតម្រូវក្នុងការតាមដាន និងរាយការណ៍។

## ៧.៤ កាលវិភាគ

៦១. ផែនការអភិវឌ្ឍជនជាតិដើមភាគតិច (IPP) នឹងត្រូវបានរៀបចំភ្លាមនៅពេលដែលទីតាំងគម្រោងជាក់លាក់ត្រូវបានជ្រើសរើស និងផលប៉ះពាល់អវិជ្ជមានលើសហគមន៍ ជនជាតិដើមភាគតិចត្រូវបានកំណត់ និងបញ្ជូនទៅកាន់ធនាគារពិភពលោក ជាផ្នែកមួយនៃផែនការអនុវត្ត។ មុនពេលចាប់ផ្តើមអនុវត្ត ត្រូវបង្ហាញ IPP នៅលើគេហទំព័ររបស់ MIH និង / ឬ MPWT និងនៅលើទំព័រព័ត៌មានInfoShop របស់ធនាគារពិភពលោក។ ឯកសារ IPP មួយច្បាប់ជាភាសាក្នុងស្រុកនឹងត្រូវតម្កល់ទុកនៅក្នុងក្រុមប្រឹក្សាឃុំនៃតំបន់គោលដៅដែលជនជាតិដើមភាគតិចអាចទៅដល់។

## ៧.៥ ថវិកា

៦២. ថវិកាសម្រាប់ការអនុវត្ត IPPF ជាផ្នែកមួយនៃថវិកាគម្រោង។ ថវិកានេះគ្របដណ្តប់លើការចំណាយលើប្រាក់ឧបត្ថម្ភបុគ្គលិកគម្រោង និងកុងស៊ុលតង់ ដើម្បីរៀបចំរបាយការណ៍អនុលោមភាព រួមទាំងរបាយការណ៍ត្រួតពិនិត្យ និងតាមដានរបាយការណ៍ ការប្រមូលទិន្នន័យ និងការរៀបចំ IPP ជាដើម។ ការប៉ាន់ស្មានថវិកាមាននៅក្នុងក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន(ESMF)។

៦៣. IPP នឹងរួមមានព័ត៌មានស្តីពីចំណាយលម្អិតនៃវិធានការកាត់បន្ថយ និងសិទ្ធិទទួលបាននីតិសម្បទាសម្រាប់ជនជាតិដើមភាគតិចនៅក្នុងតំបន់រងផលប៉ះពាល់ និងចំណាយរដ្ឋបាល និងចំណាយ តាមដាន។ ប្រភពថវិកាសម្រាប់សកម្មភាពផ្សេងៗ និងផែនការហិរញ្ញប្បទានសម្រាប់ IPP ត្រូវបាន បង្កើតក្រោយពេលដែល IPP ត្រូវបាន

បង្កើតឡើង។ ការចំណាយលើអស្សាមិករ (ការរេដកហូត) ដីធ្លី ប្រសិនបើមាន នឹងត្រូវទទួលការឧបត្ថម្ភថវិកាពីមូលនិធិរបស់សមភាគី ចំណែកឯចំណាយលើការបណ្តុះបណ្តាល និងការពិគ្រោះយោបល់នឹងត្រូវផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក (IDA) ។

# ៨. ការវាយតម្លៃសង្គមនិងការរៀបចំផែនការជនជាតិដើមភាគតិច

## ៨.១ វិធីសាស្ត្រប្រើប្រាស់សម្រាប់ការវាយតម្លៃសង្គម

៦៤. ត្រូវមានវិធីស្រាស្តដែលមានការចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃ WaSSIP ។ ដំបូងគេប្រើវិធីសាស្ត្រនេះក្នុងអំឡុងពេលប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានជាមួយសហគមន៍ ក្នុងពេលវាយតម្លៃសង្គមបឋម)។ នៅដំណាក់កាលបន្តបន្ទាប់វិធីសាស្ត្រនេះនឹងត្រូវបានប្រើសម្រាប់ការត្រួតពិនិត្យគម្រោងរៀបចំដំណាក់កាលវាយតម្លៃសង្គម (សម្រាប់ការរៀបចំ IPP) និងការអនុវត្ត និងតាមដានគម្រោង។ ដំណើរការនិងនីតិវិធីលម្អិតត្រូវបានពណ៌នានៅអនុផ្នែកខាងក្រោម។

៦៥. ការវាយតម្លៃបឋមបានបញ្ជាក់ថាជនជាតិដើមនៅក្នុងតំបន់អនុវត្តគម្រោង (ក្នុងក្រុងសែនមនោរម្យខេត្តមណ្ឌលគិរី) ជារួម នឹងទទួលបានផលវិជ្ជមានពីគម្រោង ប៉ុន្តែអាចរងផលប៉ះពាល់អវិជ្ជមានដោយសារតម្រូវការ ដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកនៅប្រភពទឹកថ្មី និងស្ថានីយ៍បូមទឹកដែលអាចស្ថិតនៅក្នុងសហគមន៍របស់ពួកគេ។

៦៦. ក្នុងកំឡុងពេលអនុវត្ត ជំហានខាងក្រោមនឹងត្រូវអនុវត្តចំពោះការពិនិត្យ ការវាយតម្លៃសង្គម និងការរៀបចំផែនការជនជាតិដើមភាគតិច។ ពត៌មានលម្អិតទាក់ទងនឹងការធ្វើការពិគ្រោះយោបល់ ការរៀបរៀងផែនការអភិវឌ្ឍជនជាតិដើមភាគតិច និងលិខិតុបករណ៍ស្តីពីវិធានការណ៍ការពារមួយចំនួនទៀតមាននៅក្នុងឧបសម្ព័ន្ធទី១។

ក) ការពិនិត្យរួមគ្នាដោយ MIH និងធនាគារពិភពលោកដើម្បីកំណត់ថាតើមានជនជាតិដើមដែរឬទេ ឬមានការជាប់ពាក់ព័ន្ធជាសមូហភាពទៅនឹងតំបន់អនុវត្តគម្រោង តំបន់គោលដៅដែរឬ យ៉ាងណា (សូមពិនិត្យទម្រង់ក្នុងឧបសម្ព័ន្ធ ២) ។

ខ) ធ្វើការវាយតម្លៃសង្គមដោយ MIH ដោយមានជំនួយពីកុងសុលតង់ដែលមានប្រវត្តិលើផ្នែកការពារសង្គម ប្រសិនបើការត្រួតពិនិត្យសន្និដ្ឋានថា មានជនជាតិដើមភាគតិច ឬមានការពាក់ព័ន្ធជាសមូហភាពទៅនឹងតំបន់អនុវត្តគម្រោង។ ភាពទូលំទូលាយ ភាពស៊ីជម្រៅ និងប្រភេទនៃការវាយតម្លៃសង្គមមានសមាមាត្រទៅនឹងសភាព និងទំហំនៃផលប៉ះពាល់ដែលអាចកើតមានពីគម្រោងដែលបានស្នើ មកលើជនជាតិដើមភាគតិច ថាតើផលប៉ះពាល់ទាំងនោះមានលក្ខណៈវិជ្ជមាន ឬអវិជ្ជមានដែរឬយ៉ាងណា។ វិធីសាស្ត្រពិគ្រោះយោបល់ដោយសេរី និងមានការជូនដំណឹងជាមុនត្រូវបានប្រើប្រាស់។

គ) ការរៀបចំផែនការជនជាតិដើមភាគតិចផ្អែកលើលទ្ធផលនការវាយតម្លៃសង្គម និងការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដែលរងគ្រោះ។ IPP នឹងធានឱ្យជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយសារគម្រោង ទទួលបានអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចសមស្របទៅតាមវប្បធម៌ និង (ខ) នៅពេលដែលរកឃើញថាមានផលប៉ះពាល់អវិជ្ជមានមកលើជនជាតិដើមភាគតិច ផលប៉ះពាល់អវិជ្ជមានទាំងនោះត្រូវបានបញ្ចៀស កាតបន្ថយឱ្យនៅតិចបំផុត បន្ធូរបន្ថយ ឬទូទាត់សំណង និង

ឃ) ការបង្ហាញសេចក្តីព្រាងផែនការជនជាតិដើមភាគតិចទៅកានសាធារណៈជន។ សេចក្តីព្រាង IPP នឹងត្រូវបង្ហោះទៅក្នុងគេហទំព័រ InfoShop របស់ធនាគារពិភពលោកព័ត៌មានពិភពលោក និងគេហទំព័ររបស់ MIH និង MPWT ហើយបកប្រែជាភាសាក្នុងស្រុក និងរក្សាទុកមួយច្បាប់នៅការិយាល័យឃុំ ហើយមួយច្បាប់ទៀតទុកនៅតំបន់ដែលជនជាតិដើមភាគតិចអាចធ្វើដំណើរចូលទៅបាន

ង) ការធ្វើបច្ចុប្បន្នភាពការវាយតម្លៃសង្គមក្នុងកំឡុងពេលអនុវត្តគម្រោងជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យដើម្បីកំណត់ផលប៉ះពាល់អវិជ្ជមានដែលមិនត្រូវបានរំពឹងទុក និងដើម្បីស្នើនូវវិធានការកាត់បន្ថយផលបះពាល់។ ប្រសិនបើផលប៉ះពាល់មានទំហំធំ IPP ក៏នឹងត្រូវធ្វើបច្ចុប្បន្នភាពផងដែរ ដើម្បីគ្របដណ្តប់លើផលប៉ះពាល់បច្ចុប្បន្ន។ វិធីសាស្ត្រពិគ្រោះយោបល់ដោយសេរីនិងជូនដំណឹងជាមុនទំនងជាត្រូវបានប្រើប្រាស់។

## ៨.២ ការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុន

៦៧. ការចូលរួមគឺជាដំណើរការមួយដែលតាមរយៈនោះភាគីពាក់ព័ន្ធធ្វើឱ្យមានឥទ្ធិពល និងបែងចែកការគ្រប់គ្រងចំពោះគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ ការសម្រេចចិត្ត និងធនធានដែលប៉ះពាល់ដល់ពួកគេ។ ការសម្រេចចិត្តចូលរួមគឺជាការចាប់ផ្តើមនៃដំណើរការចូលរួមទាំងមូលនៅក្នុងវដ្តនៃគម្រោង។ OP / BP៤.១២ របស់ធនាគារពិភពលោក និងច្បាប់របស់រាជរដ្ឋាភិបាលស្តីពីអស្សាមិករ និងនីតិវិធីអនុវត្តន៍ក្នុងការតាំងទីលំនៅជាថ្មីរបស់ IRC ផ្តល់នូវការណែនាំនិងទិសដៅច្បាស់លាស់ដល់អ្នកគាំទ្រគម្រោងទាំងក្នុងវិស័យសាធារណៈនិងឯកជនអំពីតម្រូវក្នុងការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈ និងគូសបញ្ជាក់សារៈសំខាន់នៃការជូនដំណឹងដល PAPs អំពីគម្រោងនេះ ហើយសំខាន់ជាងនេះទៅទៀតនោះ គឺការចូលរួមយ៉ាងសកម្មរបស់ពួកគេនៅក្នុងការធ្វើផែនការនិងការអនុវត្ត។

៦៨. ការចូលរួមគឺជាដំណើរការនៃការប្រាស្រ័យទាក់ទងគ្នាដ៏សកម្ម និងជាបន្តបន្ទាប់ក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន សហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ (ទោះបីវិជ្ជមាន ឬអវិជ្ជមានក្តី) ទីភ្នាក់ងារជាតិ និងក្រសួងពាក់ព័ន្ធ កុងស៊ុលតង់គម្រោងសង្គមស៊ីវិល និងទីភ្នាក់ងារម្ចាស់ជំនួយអន្តរជាតិ។ ការចូលរួមគឺជាពាក្យទូទៅក្តោប វិសាលភាពពីផ្សេងគ្នាគឺការផ្លាស់ប្តូរព័ត៌មាន (ពោលគឺ ការផ្សព្វផ្សាយ និងការពិគ្រោះយោបល់) និងទម្រង់ផ្សេងៗគ្នានៃការធ្វើសេចក្តីសម្រេចរួមគ្នា (ពោលគឺការសហការ ឬការចូលរួម)៖

៦៩. WaSSIP នឹងទទួលយកការពិគ្រោះយោបល់ពេញលេញនិងការចូលរួមរបស់ភាគីពាក់ព័ន្ធសម្រាប់សមាសភាគទី ១ និងទី ២ ។ ក្នុងអំឡុងពេលនៃការពិនិត្យគម្រោង (ដំណើរការជ្រើសរើសតំបន់អនុវត្តគម្រោង) សហគមន៍គ្រូបង្រៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋានត្រូវបានពិគ្រោះយោបល់ពេញលេញអំពីអត្ថប្រយោជន៍ និងផលប៉ះពាល់ដែលអាចកើតមាន។ ការវាយតម្លៃអំពីសង្គមនឹងត្រូវបានកំណត់ទៅនៅតំបន់គោលដៅ ដែលអាចមានផលប៉ះពាល់លើជនជាតិដើម ភាគតិច ក៏ដូចជាលើដីធ្លី និងធនធានផ្សេងទៀត។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈចំនួនពីរនឹងប្រព្រឹត្តទៅ។ សកម្មភាព WaSSIP ផលប៉ះពាល់គម្រោង និងវិធានការកាត់បន្ថយផលប៉ះពាល់នឹងត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំលើកដំបូង។ បន្ទាប់មកកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរនឹងប្រព្រឹត្តទៅដើម្បីកំណត់ថាតើមានការគាំទ្រសម្រាប់សកម្មភាពគម្រោងនិងផែនការកាត់បន្ថយផលប៉ះពាល់ដែរឬយ៉ាងណា។

៧០. មុនពេលពិគ្រោះយោបល់ CMU នឹងបញ្ជូនសេចក្តីជូនដំណឹងដល់សហគមន៍ ប្រាប់មេដឹកនាំរបស់ពួកគេថានឹងមានការចុះមកធ្វើទស្សនកិច្ចពីសំណាក់មន្ត្រីសម្របសម្រួល និងពីអាជ្ញាធរមូលដ្ឋាន ហើយការពិគ្រោះយោបល់នេះនឹងត្រូវបានធ្វើឡើងដើម្បីស្វែងរកការគាំទ្រពីអន្តរាគមន៍របស់គម្រោង និងដើម្បីកំណត់ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ក៏ដូចជាការគាំទ្រដែលគម្រោងអាចធ្វើបានដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចកើតមាន។ សេចក្តីជូនដំណឹងនេះនឹងស្នើសុំឱ្យសហគមន៍អញ្ជើញតំណាងកសិករ សមាគមន៍ស្ត្រី និងមេភូមិចូលរួមប្រជុំ។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ មេដឹកនាំសហគមន៍ និងអ្នកចូលរួមដទៃទៀត នឹងបង្ហាញទស្សនៈរបស់ពួកគេទាក់ទងទៅនឹងសកម្មភាពដែលបានស្នើសុំ។

៧១. ក្នុងកំឡុងពេលពិគ្រោះយោបល់នីតិវិធីលម្អិតនឹងត្រូវបានកំណត់ទៅតាមភូមិនីមួយៗ ដើម្បីកំណត់ផលប៉ះពាល់ដែលអាចកើតមាន និងការគាំទ្រដែលអាចមាន នៅក្រោម WaSSIP ។ លើសពីនេះទៀត ប្រព័ន្ធដោះស្រាយជម្លោះតាមរយៈយន្តការសារទុក្ខ ដែលបានបង្កើតឡើង នឹងត្រូវបានកំណត់ដើម្បីធានាឱ្យមានការឆ្លុះបញ្ចាំងសម្លេងរបស់ប្រជាជនដែលរងផលប៉ះពាល់ (ជាពិសេសចំពោះលទ្ធកម្មដី) ។ ប្រសិនបើសហគមន៍ទទួលផលរួមបញ្ចូលសហគមន៍ជនជាតិភាគតិចដែលមិនមែនជាសមាជិកនៃក្រុមជនជាតិភាគតិចភាគច្រើននៃសហគមន៍ នោះអ្នកតំណាងរបស់ពួកគេនឹងត្រូវបានបញ្ចូលទៅក្នុងយន្តការដោះស្រាយជម្លោះ។ ការណ៍នេះធានាបាននូវភាពសមស្របផ្នែកវប្បធម៌ និងការចូលរួមរបស់សហគមន៍ជាពិសេសក្រុមជនជាតិភាគតិចនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

៧២. នៅក្នុងដំណើរការនេះការពិគ្រោះយោបល់ដោយសេរី និងការផ្តល់ដំណឹងជាមុននឹងប្រព្រឹត្តទៅដោយប្រើភាសាដែលនិយាយ និងប្រព្រឹត្តនៅទីតាំងដែលងាយស្រួលសម្រាប់ជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់។ ទស្សនៈរបស់ជនជាតិដើមភាគតិចត្រូវយកមកពិចារណាក្នុងអំឡុងពេលអនុវត្តន៍ WaSSIPs ទន្ទឹមនឹងការអនុវត្តជាក់ស្តែងនូវជំនឿ និងចំណង់ចំណូលចិត្តផ្នែកវប្បធម៌របស់ពួកគេ។ លទ្ធផលនៃការពិគ្រោះយោបល់នេះនឹងត្រូវបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍តាមកាលកំណត់និងដាក់ជូនធនាគារពិភពលោកត្រួតពិនិត្យ។

៧៣. ក្នុងកំឡុងពេលអនុវត្ត WaSSIP ការវាយតម្លៃសង្គមដែលត្រូវបានធ្វើបច្ចុប្បន្នភាពក៏ត្រូវបានអនុវត្តផងដែរ ដើម្បីតាមដានផលវិជ្ជមាន និងផលបះពាល់អវិជ្ជមាននៃគម្រោង និងទទួលបានមតិយោបល់ពីប្រជាជនដែលទទួលរងផលប៉ះពាល់ពីគម្រោង។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃសង្គម ត្រូវចាត់វិធានការបន្ថែម ដើម្បីធានាផលប្រយោជន៍ពេញលេញ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលបានប្រមើលមើល។ ប្រសិនបើចាំបាច់ត្រូវអនុវត្តសកម្មភាពបន្ថែមសម្រាប់ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពរបស់ សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់អនុវត្តគម្រោង។ ប្រសិនបើផលប៉ះពាល់មិនបានរំពឹងទុកមានទំហំធំ ត្រូវធ្វើបច្ចុប្បន្នភាព IPP និង / ឬ RAP។

# ឧបសម្ព័ន្ធទី ១: គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការពិគ្រោះយោបល់ និងការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPP) ព្រមទាំងឯកសារស្តីពីវិធានការការពារផ្សេងទៀត

## ការពិគ្រោះយោបល់

១. ក្របខ័ណ្ឌពិគ្រោះយោបល់ត្រូវបានរៀបចំឡើងដើម្បីជួយធានាឱ្យមានការជូនដំណឹង ការពិគ្រោះយោបល់ និងការកៀរជនជាតិដើមភាគតិច ឱ្យចូលរួមក្នុងការវិនិយោគ ដែលគាំទ្រដោយ WaSSIP ។ ការចូលរួមរបស់ពួកគេនឹងមិនត្រឹមតែធ្វើឱ្យការគ្រប់គ្រងទឹកស្អាតមាននិរន្តភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់អត្ថប្រយោជន៍កាន់តែច្បាស់ថែមទៀត ឬផ្តល់ការការពារពួកគេពីផលប៉ះពាល់អវិជ្ជមាននៃការវិនិយោគ ដែលផ្តល់ហិរញ្ញប្បទានដោយគម្រោង។ លក្ខណៈពិសេស / នីតិវិធីសំខាន់ៗនៃក្របខ័ណ្ឌពិគ្រោះយោបល់ រួមមាន ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីកំណត់កំរិត និងសភាពនៃផលប៉ះពាល់ដែលគាំទ្រដោយគម្រោង។ ផែនការអភិវឌ្ឍជនជាតិដើមភាគតិច (IPP) នឹងត្រូវបានបង្កើតឡើងប្រសិនបើសហគមន៍ជនជាតិដើមភាគតិចត្រូវបានរកឃើញថាមានវត្តមាននៅក្នុង ឬមានការផ្សាភ្ជាប់ជាសមូហភាពទៅនឹងតំបន់ដែលរងផលប៉ះពាល់ក្រោមផែនការអនុវត្តគម្រោងនីមួយៗ។ ការពិគ្រោះយោបល់ជាមួយ និងការចូលរួមរបស់ជនជាតិដើម ភាគតិច ក៏ដូចជាជាមួយមេដឹកនាំរបស់ពួកគេ និងជាមួយមន្ត្រីរដ្ឋាភិបាលមូលដ្ឋានគឺជាផ្នែកសំខាន់នៃ IPP ទាំងមូលដែលគួរតែត្រូវបានរៀបចំរួមជាមួយរបាយការណ៍គម្រោងចាំបាច់ផ្សេងទៀត។

២. ការជ្រើសរើសតំបន់គោលដៅនឹងប្រព្រឹត្តទៅក្នុងពេលពិនិត្យគម្រោងដោយប្រើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម:

(i) តំបន់ដែលបង្ហាញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះទស្សនទាននៃគម្រោងហើយមានឆន្ទៈបំពេញតាមបុរេលក្ខខណ្ឌរបស់គម្រោងសម្រាប់ការជ្រើសរើស។ និង
(ii) តំបន់ដែលមានតម្រូវការផ្គត់ផ្គង់ទឹកខ្ពស់។

៣. ដំណើរការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុនទាក់ទងនឹងក្រុមជនជាតិដើមភាគតិចនឹងផ្តល់ទិន្នន័យគោលទូលំទូលាយមួយលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងបច្ចេកទេសនៃការវិនិយោគនីមួយៗ ជាពិសេសចំពោះតំបន់ដែលបានពិនិត្យឃើញថាមានក្រុមជនជាតិភាគតិចរស់នៅក្នុងអំឡុងពេលពិនិត្យ (រៀបចំ) គម្រោង។ ការណ៍នេះក៏រាប់បញ្ចូលផងដែរនូវការកសាងផែនទីដោយមានការចូលរួម ដើម្បីកំណត់ទីតាំងពិតប្រាកដនៃការដ្ឋានសំណង់ ក៏ដូចជាតម្រូវការទំហំដី និងទីតាំងរបស់សហគមន៍ជនជាតិដើមផងដែរ។ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យជនជាតិដើម ភាគតិចនឹងបង្ហាញថាតើមាន ឬគ្មានជនជាតិដើមភាគតិចមាននៅក្នុងតំបន់អនុវត្តគម្រោងដែរឬយ៉ាងណា និងកំណត់ពីបញ្ហាសង្គមដែលអាចកើតមានមកលើជនជាតិដើមភាគតិចបណ្តាលមកពីការវិនិយោគ។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម / ក្រសួងសាធារណៈការ និងដឹកជញ្ជូន នឹងអនុវត្តវិធានការជាក់លាក់ដើម្បីពិគ្រោះ

យោបល់ជាមួយជនជាតិដើមភាគតិច និងផ្តល់ឱកាសឱ្យពួកគាត់ចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងការវិនិយោគប្រសិនបើពួកគាត់ចង់ចូលរួម។

៤. តំបន់គោលដៅទាំងអស់ដែលមានសហគមន៍ជនជាតិដើមភាគតិច និងជាបេក្ខភាពសម្រាប់ការគាំទ្ររបស់គម្រោងនឹងត្រូវបានធ្វើទស្សនកិច្ច (ក្នុងពេលពិគ្រោះយោបល់លើកដំបូងជាមួយសហគមន៍) ដោយក្រុមការងាររបស់ CMU រួមមានមន្ត្រីសម្របសម្រួលផ្នែកការពារសង្គម និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ រួមមានបុគ្គលិកដែលមានការបណ្តុះបណ្តាលឬមានបទពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គម ។ មុនពេលធ្វើទស្សនកិច្ច CMU នីមួយៗនឹងជូនដំណឹងដល់សហគមន៍ ប្រាប់មេដឹកនាំរបស់ពួកគេថាមន្ត្រីសម្របសម្រួល និងអាជ្ញាធរមូលដ្ឋាននឹងចុះមកជួបពួកគាត់ ហើយនឹងមានការពិគ្រោះយោបល់ ដើម្បីស្វែងរកការគាំទ្រពីអន្តរាគមន៍របស់គម្រោង និងកំណត់ផលប៉ះពាល់អវិជ្ជមាន ក៏ដូចជាការគាំទ្រពីគម្រោងដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចកើតមានផងដែរ។ សេចក្តីជូនដំណឹងនេះនឹងស្នើឱ្យសហគមន៍អញ្ជើញតំណាងកសិករ សមាគមន៍នារី និងមេភូមិ ចូលរួមប្រជុំ។ ក្នុងអំឡុងពេលនៃការធ្វើទស្សនកិច្ចនេះមេដឹកនាំសហគមន៍ និងអ្នកចូលរួមដទៃទៀតនឹងបង្ហាញទស្សនៈរបស់ពួកគេទាក់ទងទៅនឹងសកម្មភាពដែលបានស្នើ។

៥. WaSSIP នឹងកំណត់ និងប្រើប្រាស់យន្តការបណ្តឹងសារទុក្ខរបស់សហគមន៍ដែលមានស្រាប់ដើម្បីពិចារណាអំពីអត្តសញ្ញាណវប្បធម៌ជាក់លាក់ ក៏ដូចជាយន្តការវប្បធម៌ប្រពៃណីដើម្បីលើកឡើងនិងដោះស្រាយបញ្ហានានា សំដៅទទួលបាន និងដោះស្រាយការព្រួយបារម្ភរបស់ក្រុមជនជាតិភាគតិចក្នុងកំឡុងពេលរៀបចំគម្រោង ការអនុវត្តគម្រោង និងក្រោយពីការបញ្ចប់គម្រោង។ ដើម្បីសម្រេចបានបែបនេះ គម្រោងនឹង (ក) រិះរកនិងកំណត់វិធីដែលអាចទទួលយកបានតាមបែបវប្បធម៌ ដើម្បីដោះស្រាយបណ្តឹងសារទុក្ខចំពោះក្រុមជនជាតិភាគតិចដែលមានលក្ខណៈខុសគ្នាជាខ្លាំងនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ រួមទាំងក្រុមជនជាតិពិន្ទុ ឬក្រុមដែលមានវប្បធម៌ផ្សេងគ្នានៅក្នុងតំបន់ដែលរងផលប៉ះពាល់ពីគម្រោង។ (ខ) យល់អំពីអត្តសញ្ញាណវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ដែលអាចជះឥទ្ធិពល ឬរារាំងដល់សមត្ថភាពរបស់ពួកគេ ក្នុងការបង្ហាញសារទុក្ខរបស់ពួកគេ រាប់បញ្ចូលទាំងភាពខុសគ្នាអំពីតួនាទី និងការទទួលខុសត្រូវរបស់ អនុក្រុម (ជាពិសេសស្ត្រី) និងចំណុចរសើប ការហាមប្រាមផ្នែកវប្បធម៌។ និង (គ) យល់ស្របលើវិធីប្រសើរបំផុតដើម្បីទទួលបានយន្តការបណ្តឹងសារទុក្ខ ដោយពិចារណាអំពីវិធីដែលសហគមន៍ សម្តែងមតិ និងរកដំណោះស្រាយចំពោះសារទុក្ខ។

៦. ក្នុងពេលទស្សនកិច្ចនេះ មន្ត្រីសម្របសម្រួលរបស់ CMU ឬមន្ត្រីពាក់ព័ន្ធដែលមានជំនាញសង្គមនឹងធ្វើការពិនិត្យជនជាតិដើមភាគតិច ដោយមានជំនួយពីមេដឹកនាំជនជាតិដើមភាគតិច និង អាជ្ញាធរមូលដ្ឋាន។ ការពិនិត្យនឹងផ្តោតលើចំណុចដូចខាងក្រោម:

ក) ឈ្មោះក្រុមជនជាតិនៅតាមភូមិ / ឃុំដែលរងផលប៉ះពាល់។
ខ) ចំនួនក្រុមជនជាតិភាគតិចនៅក្នុងភូមិ / ឃុំដែលរងផលប៉ះពាល់។
គ) ភាគរយជនជាតិដើមនៅតាមភូមិ / ឃុំដែលរងផលប៉ះពាល់ និង

ឃ) ចំនួននិងភាគរយនៃគ្រួសារជនជាតិភាគតិចក្នុងតំបន់ដែលរងឥទ្ធិពលពីសំណើវិនិយោគ។ (តំបន់រងឥទ្ធិពលត្រូវរួមបញ្ចូលគ្រប់កន្លែងទាំងអស់ដែលការវិនិយោគទំនងជាផ្តល់អត្ថប្រយោជន៍ និងធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមាន។ )

៧. នៅពេលដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម / ក្រសួងសាធារណការ និងដឹកជញ្ជូន បានជ្រើសរើសតំបន់គោលដៅរួចហើយ តាមរយៈដំណើរការពិនិត្យ និងផលប៉ះពាល់ដែលអាចកើតមានចំពោះជនជាតិដើមភាគតិច នោះនឹងមានការវាយតម្លៃផលប៉ះពាល់សង្គម ដោយប្រើប្រាស់បញ្ជីសារពើភ័ណ្ឌលើទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ អង្កេតសេដ្ឋកិច្ចសង្គមកិច្ច និងវិធីសាស្ត្រវាយតម្លៃរហ័សដែលមានការចូលរួម (PRA) ។ សាវតាសង្គម និងសេដ្ឋកិច្ចរបស់អ្នកទទួលផល ឬអ្នករងផលប៉ះពាល់ពីគម្រោងនឹងត្រូវបានបម្រែប្រមូល។ ការពិគ្រោះយោបល់ដោយសេរី និងផ្តល់ដំណឹងជាមុននឹងត្រូវអនុវត្តចំពោះអ្នកទទួលផល / សហគមន៍ / ភូមិដែលរងផលប៉ះពាល់ និងឃុំនានាដោយបញ្ជាក់ពីការ គាំទ្រសហគមន៍ទូលំទូលាយរបស់ពួកគេ និងកំណត់ផលប៉ះពាល់ដែលអាចកើតមាននិងការគាំទ្រដែលអាចទទួលបានពីគម្រោង។ លទ្ធផលនៃដំណើរការនេះគឺជា មូលដ្ឋានដើម្បីបង្កើតឯកសារការពារ ជាផ្នែកមួយនៃផែនការអនុវត្តគម្រោងដែលរួមមាន:

- ***ផែនការប្រជាជនជនជាតិដើមភាគតិច (IPP)*** ត្រូវបានបង្កើតឡើងក្រោមកម្មវិធី WaSSIP ។ ទម្រង់នៃ IPP ត្រូវបានពិពណ៌នាក្រោមអនុផ្នែកនៃឯកសារនេះ។
- ***ផែនការសកម្មភាពតាំងទីលំនៅជាថ្មី (RAP)*** ត្រូវបានបង្កើតឡើងប្រសិនបើមានលទ្ធកម្មដីធ្លី។ ទម្រង់នៃ RAP និងគោលការណ៍ណែនាំសម្រាប់រៀបចំមានពិពណ៌នានៅក្នុងក្របខ័ណ្ឌគោលនយោបាយការតាំងលំនៅជាថ្មី (RPF) ។ ឬ
- ត្រូវរៀបចំ***របាយការណ៍ត្រួតពិនិត្យ***ប្រសិនបើគ្មានលទ្ធកម្មដីធ្លី ឬគ្មានផលប៉ះពាល់ទៅលើជនជាតិដើមភាគតិច។

៨. ប្រសិនបើផលប៉ះពាល់ដែលមិនបានរំពឹងទុក (ទាំងលើជនជាតិដើមភាគតិច ឬទាំងលទ្ធកម្មដីធ្លី) កើតមានឡើងក្នុងកំឡុងពេលអនុវត្តគម្រោង (ជាពិសេសអំឡុងពេលសាងសង់) ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាព IPP និង RAP ។ IPP និង RAP ត្រូវអនុវត្តមុនពេលចាប់ផ្តើមសាងសង់។

តារាង ១A: តារាងម៉ាទ្រីសនៃដំណាក់កាលគម្រោង និងឯកសារការពារដែលត្រូវមាន

| ដំណាក់កាលគម្រោង | ការជ្រើសរើសតំបន់គោលដៅជាមុន<br>(ទស្សនាទានគម្រោង) | ការជ្រើសរើសតំបន់គោលដៅ<br>(ការពិនិត្យគម្រោង) | តំបន់គោលដៅដែលបានជ្រើសរើស និងផលប៉ះពាល់ដែលអាចកើតមាន<br>(ការអនុម័តតំបន់គោលដៅ) | ការសាងសង់ សម្បទាផ្គត់ផ្គង់ទឹក<br>(ការអនុវត្តគម្រោង) |
|---|---|---|---|---|
| **ការវាយតម្លៃ** | ការវាយតម្លៃសង្គម | ការពិនិត្យការការពារ | ការវាយតម្លៃសង្គម | ការវាយតម្លៃសង្គមដែលបានធ្វើបច្ចុប្បន្នភាព |
| **ការការពារដែលតម្រូវឱ្យមាន** | ការរៀបចំជាតុចូល IPPF និង RPF ដើម្បីដាក់បញ្ចូលទៅក្នុង ESMF | • បញ្ជីតំបន់គោលដៅដែលអាចរងផលប៉ះពាល់<br>• រៀបចំ DDR សម្រាប់តំបន់ដែលគ្មានផលប៉ះពាល់<br>• ចងក្រងឯកសារនៃកិច្ចប្រជុំពិគ្រោះយោបល់ | • រៀបចំ IPP<br>• រៀបចំ RAP ប្រសិនបើបានធ្វើលទ្ធកម្មដី | • បច្ចុប្បន្នភាពនិងការអនុវត្ត IPP និង RAP<br>• របាយការណ៍តាមដាន |

**ការវាយតម្លៃសង្គម**

៩. បន្ថែមលើការវាយតម្លៃសង្គមដែលបានអនុវត្តនៅពេលជ្រើសរើសតំបន់គោលដៅជាមុនការវាយតម្លៃសង្គមនឹងប្រព្រឹត្តទៅក្នុងចំណោមតំបន់គោលដៅដែលអាចរងផលប៉ះពាល់ហើយដែលត្រូវបានជ្រើសរើស។ ការវាយតម្លៃសង្គមនឹងដឹកនាំដោយអ្នកឯកទេស អភិវឌ្ឍន៍សង្គមដែលមានគុណវុឌ្ឍិមានចំណេះដឹងអំពីវប្បធម៌របស់ជនជាតិ

ភាគតិចដែលពាក់ព័ន្ធ។ នៅដំណាក់កាលនេះការវាយតម្លៃសង្គមមិនត្រឹមតែប្រមូលព័ត៌មានដែលទាក់ទងទៅនឹងទិន្នន័យប្រជាសាស្ត្រ ស្ថានភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏ប្រមូលព័ត៌មានអំពីផលប៉ះពាល់របស់គម្រោង និងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច រួមទាំងផលវិជ្ជមាន ឬអវិជ្ជមានផងដែរ។ វិសាលភាព ជម្រៅ និងប្រភេទនៃការវិភាគដែលតម្រូវឱ្យមានការវាយតម្លៃសង្គមមានលក្ខណៈសមាមាត្រ ទៅនឹងសភាព និងទំហំនៃផលប៉ះពាល់ដែលអាចកើតមានពីសំណើគម្រោងមកលើជនជាតិដើមភាគតិច។ លទ្ធផលនៃការវាយតម្លៃនេះនឹងត្រូវបានប្រើដើម្បីរៀបចំ IPP ។

១០. ការវាយតម្លៃសង្គមរួមមានធាតុមួយចំនួនដូចខាងក្រោម តាមការចាំបាច់:

ក ការពិនិត្យឡើងវិញដែលមានទំហំសមស្របទៅនឹងគម្រោង អំពីក្របខ័ណ្ឌច្បាប់និងស្ថាប័នដែលអនុវត្តចំពោះជនជាតិដើមភាគតិច។

ខ ការប្រមូលព័ត៌មានគោលអំពីលក្ខណៈប្រជាសាស្ត្រ សង្គម វប្បធម៌ និងនយោបាយរបស់ សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដីធ្លី និងដែនដីដែលពួកគេធ្លាប់មាន ឬ ប្រើប្រាស់ប្រើប្រាស់ជាលក្ខណៈប្រពៃណី និងធនធានធម្មជាតិដែលពួកគេពឹងអាស្រ័យ។

គ ការពិនិត្យឡើងវិញនូវព័ត៌មានគោល និងអត្តសញ្ញាណកម្មភាគីពាក់ព័ន្ធសំខាន់ៗ និងការបង្កើតដំណើរការសមស្របផ្នែកវប្បធម៌ ដើម្បីពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច នៅដំណាក់កាលនីមួយៗនៃការរៀបចំនិងការអនុវត្តគម្រោង។

ឃ ការវាយតម្លៃផ្អែកលើការពិគ្រោះយោបល់ដោយសេរី និងផ្តល់ដំណឹងជាមុន ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ អំពីផលប៉ះពាល់អវិជ្ជមាន និងផលវិជ្ជមាននៃ គម្រោង។ ការវិភាគពីភាពងាយរងគ្រោះ និងហានិភ័យចំពោះសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ក្នុងកាលៈទេសៈដោយឡែក និងមានសម្ព័ន្ធភាពជិតស្និទ្ធទៅនឹង ដីធ្លី និងធនធានធម្មជាតិ ក៏ដូចជាកង្វះលទ្ធភាពទទួលបានឱកាសនានាធៀបនឹងក្រុមសង្គមផ្សេងទៀតនៅក្នុងសហគមន៍ នៅក្នុងតំបន់ ឬនៅក្នុងសង្គមជាតិដែលពួកគេរស់នៅ។

ង ការកំណត់អត្តសញ្ញាណនិងការវាយតម្លៃដោយផ្អែកលើការពិគ្រោះយោបល់ដោយសេរី និង ផ្តល់ដំណឹងជាមុនដល់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ អំពីវិធានការចាំបាច់ដើម្បីបញ្ចៀសឥទ្ធិពលអវិជ្ជមាន ឬប្រសិនបើវិធានការទាំងនោះមិនអាចធ្វើទៅបាន ការកំណត់អត្តសញ្ញាណវិធានការនានាដើម្បីកាត់បន្ថយ សម្រាល ឬទូទាត់សងចំពោះផលប៉ះពាល់បែបនេះ និងលៃយ៉ាងណាឱ្យជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍ផ្នែកវប្បធម៌សមស្របពីគម្រោង។

១១. ការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុននឹងប្រព្រឹត្តទៅតាមរយៈការប្រជុំជាបន្តបន្ទាប់ រួមមានការប្រជុំក្រុមដោយឡែក គឺប្រធានភូមិជនជាតិភាគតិច បុរសជនជាតិភាគតិច; និងស្ត្រី ជនជាតិភាគតិច ពិសេសប្រជាជនដែលរស់នៅក្នុងតំបន់រងឥទ្ធិពលពីសំណើគម្រោងនៅក្នុងតំបន់គោលដៅ។ ការពិគ្រោះយោបល់ទាំងអស់

ប្រព្រឹត្តទៅនៅទីកន្លែងដែលងាយទៅដល់។ ការពិគ្រោះយោបល់ទាំងអស់ត្រូវធ្វើជាភាសានៅមូលដ្ឋានពាក់ព័ន្ធ។ ការពិភាក្សានឹងផ្តោតទៅលើផលប៉ះពាល់នៃការវិនិយោគ ទាំងវិជ្ជមាន និងអវិជ្ជមាន និងផ្តោតលើអនុសាសន៍សម្រាប់រៀបចំប្លង់នៃការវិនិយោគ។ នៅក្នុងកិច្ចប្រជុំពិភាក្សាជាបន្តបន្ទាប់ ប្រសិនបើសហគមន៍ប្រានចោលសំណើក្រោយពីវិធានការទាំងអស់ក្នុងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានត្រូវបានពិចារណា ការវិនិយោគនោះនឹងមិនត្រូវបានអនុម័តទេ (ដូច្នេះមិនតម្រូវឱ្យមានសកម្មភាពបន្ថែមទៀតឡើយ)។

១២. ការវាយតម្លៃសង្គមដែលបានធ្វើបច្ចុប្បន្នភាពក៏នឹងត្រូវអនុវត្តតាមកាលវេលា ក្នុងអំឡុងពេលការអនុវត្តគម្រោងដែលជាផ្នែកមួយនៃដំណើរការតាមដាន ក្នុងការកំណត់រកផលប៉ះពាល់អវិជ្ជមានមិនរំពឹងទុក និងក្នុងការស្នើឱ្យមានវិធានការកាត់បន្ថយផលប៉ះពាល់។ បទពិសោធន៍ពីគម្រោងមុនៗ បង្ហាញពីផលប៉ះពាល់អវិជ្ជមានមិនបានរំពឹងទុកដែលបានកើតឡើងកំឡុងពេលសាងសង់ ឬ បណ្តាលមកពីបញ្ហាដែលត្រូវបានមើលរំលង ក្នុងកំឡុងពិនិត្យគម្រោង។ ប្រសិនបើផលប៉ះពាល់មានទំហំធំ IPP នឹងត្រូវធ្វើបច្ចុប្បន្នភាពដោយផ្អែកលើ លទ្ធផលនៃការវាយតម្លៃសង្គមដែលបានធ្វើបច្ចុប្បន្នភាព។ ដំណើរការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុនទំនងជាត្រូវបានអនុវត្ត។

## ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPP)

១៣. ផ្អែកលើមូលដ្ឋាននៃការវាយតម្លៃសង្គម និងការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ CMU នឹងរៀបចំផែនការជនជាតិដើមភាគតិច (IPP) ដែលដាក់ចេញនូវវិធានការនានាដែលតាមរយៈនោះ WaSSIP នឹងធានាថា (ក) ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយសារគម្រោងនេះ ទទួលបានអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចសមរម្យផ្នែកវប្បធម៌ និង (ខ) នៅពេលដែលបានរកឃើញផលប៉ះពាល់អវិជ្ជមានមកលើជនជាតិដើមភាគតិច ផលប៉ះពាល់អវិជ្ជមានទាំងនោះត្រូវបានបញ្ចៀស បង្រួមឱ្យនៅតិចបំផុត បន្ធូរបន្ថយ ឬទូទាត់សំណង។ IPP ត្រូវបានរៀបចំឡើងក្នុងលក្ខណៈដែលអាចបត់បែននិងជាក់ស្តែង ហើយកម្រិតលម្អិតរបស់វាប្រែប្រួល អាស្រ័យលើគម្រោងជាក់លាក់ និងសភាពនៃផលប៉ះពាល់ដែលត្រូវ ដោះស្រាយ។ អ្នកខ្ចីដាក់បញ្ចូល IPP ទៅក្នុងការរចនាគម្រោង។ នៅពេលជនជាតិដើមភាគតិចជាអ្នកទទួលផលតែមួយគត់ ឬភាគច្រើនលើសលុបនៃជនជាតិដើមភាគតិចនៃអ្នកទទួលផលពីគម្រោងដោយផ្ទាល់ នោះធាតុផ្សំនានានៃ IPP គួរតែដាក់បញ្ចូលក្នុងការរចនាគម្រោងទាំងមូលហើយ មិនចាំបាច់មាន IPP ដាច់ដោយឡែកឡើយ។ ក្នុងករណីទាំងនេះ ឯកសារវាយតម្លៃគម្រោង (PAD) រួមបញ្ចូលនូវសេចក្តីសង្ខេបខ្លីៗអំពីរបៀបដែលគម្រោងអនុវត្តតាមគោលនយោបាយជាពិសេសតាមតម្រូវការរបស់ IPP ។

១៤. តាមការចាំបាច់ IPP រួមមានធាតុផ្សំដូចខាងក្រោម:

(a) ខ្លឹមសារសង្ខេបនៃព័ត៌មានអំពី (ក) ក្របខ័ណ្ឌច្បាប់និងស្ថាប័នអនុវត្តចំពោះជនជាតិដើមភាគតិច និង (ខ) ព័ត៌មានគោលអំពីលក្ខណៈប្រជាសាស្ត្រ សង្គម វប្បធម៌ និងនយោបាយ របស់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដីធ្លី និងដែនដីដែលពួកគេធ្លាប់មាន កម្មសិទ្ធិ ឬប្រើប្រាស់តាមបែបប្រពៃណី

ឬដែលបានកាន់កាប់ និងធនធានធម្មជាតិដែលពួកគេពឹងអាស្រ័យ។

(b) សេចក្តីសង្ខេបនៃការវាយតម្លៃសង្គម

(c) ខ្លឹមសារសង្ខេបលទ្ធផលនៃការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុន ជាមួយ សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ត្រូវបានអនុវត្តក្នុងអំឡុងពេលរៀបចំគម្រោង និងដែលនាំឱ្យមានការគាំទ្រពីសហគមន៍យ៉ាងទូលំទូលាយចំពោះគម្រោង។

(d) ក្របខ័ណ្ឌមួយដែលធានាឱ្យមានការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុនជាមួយសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ក្នុងអំឡុងពេលអនុវត្តន៍គម្រោង។

(e) ផែនការសកម្មភាពនៃវិធានការដើម្បីធានាឱ្យជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ច ដែលស្របតាមវប្បធម៌ រួមទាំងវិធានការដើម្បីលើកកំពស់សមត្ថភាពរបស់ទីភ្នាក់ងារអនុវត្តន៍គម្រោង ប្រសិនបើចាំបាច់។

(f) នៅពេលដែលរកឃើញថាមានផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច នោះផែនការសកម្មភាពសមស្របអំពីវិធានការបញ្ចៀស បង្រួមផលប៉ះពាល់ឱ្យនៅតូចបំផុត បន្ធូរបន្ថយ ឬផ្តល់សំណងចំពោះផលប៉ះពាល់អវិជ្ជមានទាំងនេះ។

(g) ការប៉ាន់ស្មានការចំណាយនិងផែនការហិរញ្ញប្បទានសម្រាប់ IPP ។

(h) នីតិវិធីដែលអាចប្រើប្រាស់សមស្របទៅនឹងគម្រោងក្នុងការដោះស្រាយបណ្តឹងសារទុក្ខពីសំណាក់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដែលកើតចេញមកពីការអនុវត្តគម្រោង។ នៅពេលដែលរៀបចំនីតិវិធីបណ្តឹងសារទុក្ខ រដ្ឋាភិបាលត្រូវគិតពិចារណាអំពីអត្ថិភាពនៃយន្តការឧបាស្រ័យតាមផ្លូវតុលាការ និងយន្តការដោះស្រាយវិវាទតាមទម្លាប់ក្នុងចំណោមជនជាតិដើមភាគតិច។

(i) យន្តការនិងគោលខ្នាតដែលសមស្របទៅនឹងគម្រោងសម្រាប់ការតាមដាន ការវាយតម្លៃ និងការរាយការណ៍អំពីការអនុវត្ត IPP ។ យន្តការតាមដាន និងវាយតម្លៃគប្បីរួមបញ្ចូលការរៀបចំឱ្យមានការពិគ្រោះយោបល់ដោយសេរីនិងផ្តល់ដំណឹងជាមុនជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់។

១៥. ដើម្បីរៀបចំ IPP ចាំបាច់ត្រូវមានព័ត៌មានខាងក្រោម:

- ការជំរឿនជាមូលដ្ឋាន ទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ច និងបញ្ជីសារពើភណ្ឌនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់។
- កម្មសិទ្ធភាពរបស់គ្រួសារលើទ្រព្យសម្បត្តិសេដ្ឋកិច្ច និងមធ្យោបាយផលិត
- ប្រាក់ចំណូលប្រចាំឆ្នាំពីឱកាសការងារបឋម និងពីឱកាសការងារបន្ទាប់បន្សំ
- ព័ត៌មានសេដ្ឋកិច្ចរបស់សហគមន៍ ( ឧទាហរណ៍ ព័ត៌មានសង្ខេបស្តីពីធនធានសេដ្ឋកិច្ច ធនធានធម្មជាតិ ប្រព័ន្ធផលិតកម្មនិងការចិញ្ចឹមជីវិត ប្រព័ន្ធកម្មសិទ្ធិ )
- ពត៌មានសង្គមរបស់សហគមន៍ ( ឧទាហរណ៍ ការពិពណ៌នាអំពីទំនាក់ទំនងសាច់ញាតិ ប្រព័ន្ធតម្លៃ ប្រភេទអង្គការសង្គមនៃក្រុមក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ )

- ផលប៉ះពាល់ដែលអាចកើតមាននៃសកម្មភាពគម្រោងដែលបានស្នើឡើងមកលើសេវាកម្មសង្គមមូលដ្ឋាន (ឧទាហរណ៍ ការផ្គត់ផ្គង់ទឹក មន្ទីរព្យាបាល និងសាលារៀន)
- ផលប៉ះពាល់ដែលអាចកើតមាននៃសកម្មភាពគម្រោងមកលើជីវភាពសង្គមនិងសេដ្ឋកិច្ច។

# ឧបសម្ព័ន្ធទី ២: ការពិនិត្យបឋមចំពោះជនជាតិដើមភាគតិច

| | |
|---|---|
| **ពេលណាត្រូវពិនិត្យ?** | ពេលពិគ្រោះយោបល់លើកដំបូងជាមួយឃុំ / ភូមិ |
| **តើត្រូវប្រមូលព័ត៌មានអ្វី?** | ទិន្នន័យប្រជាសាស្ត្ររបស់ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់អនុវត្តគម្រោង |
| **តើត្រូវប្រមូលព័ត៌មានយ៉ាងដូចម្តេច?** | អាចទទួលព័ត៌មានពីមេដឹកនាំជនជាតិ មេភូមិ និងមេឃុំ |
| **តើនរណាជាអ្នកពិនិត្យ?** | កុងស៊ុលតង់ ឬ CMU |

**ខេត្ត:** ___________ **ស្រុក:** ____________ **ឃុំ:** ____________

| ឈ្មោះភូមិនៅក្នុងតំបន់អនុវត្តគម្រោង | ឈ្មោះក្រុមជនជាតិដើមនៅក្នុងតំបន់អនុវត្តគម្រោង | ចំនួនគ្រួសាររបស់ជនជាតិដើមភាគតិច | ចំនួនជនជាតិដើមភាគតិច | |
|---|---|---|---|---|
| | | | សរុប | ស្ត្រី |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |